រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# អភិវឌ្ឍន៍វិស័យប្រៃសណីយ៍
# ២០២២-២០៣០



រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# អភិវឌ្ឍន៍វិស័យប្រៃសណីយ៍
# ២០២២-២០៣០

" អភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍
ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជន ប្រកបដោយប្រសិទ្ធភាព
និរន្តរភាព និងនវានុវត្តន៍ សំដៅចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ "

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**

**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២២**

# មាតិកា

ទំព័រ


**បុព្វកថា** ........................................................ i

**អារម្ភកថា** ........................................................ iii

**បញ្ជីពាក្យកាត់** ........................................................ vi

**ខ្លឹមសារសង្ខេប** ........................................................ vii

**១- សេចក្តីផ្តើម** ........................................................ ១

**២- ស្ថានភាពវិស័យប្រៃសណីយ៍នៅកម្ពុជា** ........................................................ ២

២.១- ដំណើរវិវត្ត ........................................................ ២

២.២- កត្តាអំណោយផល និងបញ្ហាប្រឈម ........................................................ ៤

**៣- ចក្ខុវិស័យ** ........................................................ ៧

**៤- គោលបំណងនិងគោលដៅ** ........................................................ ៧

៤.១- គោលបំណង ........................................................ ៧

៤.២- គោលដៅ ........................................................ ៧

**៥- យុទ្ធសាស្ត្រ** ........................................................ ៨

៥.១- ពង្រឹងក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ ........ ៨

៥.២- បង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ ........ ៩

៥.៣- លើកកម្ពស់សុវត្ថិភាពការងារ និងចីរភាពបរិស្ថានក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍ .... ១០

៥.៤- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញភស្តុភារកម្មប្រៃសណីយ៍ និងជំរុញការធ្វើបរិវត្តកម្មឌីជីថលលើប្រព័ន្ធអេកូឡូហ្ស៊ីប្រៃសណីយ៍ សេវាកម្ម និងបណ្តាញប្រៃសណីយ៍ .. ១១

៥.៥- គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មផ្តល់សេវា ក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន ........................................................ ១២

៥.៦- ជំរុញការបង្កើនសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជា ក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម........ ១៤

៥.៧- បង្កើតកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល និងចូលរួមគាំទ្រផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល ........................................................ ១៥

៥.៨- ជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យប្រៃសណីយ៍ ............. ១៦

**៦- ផែនការសកម្មភាព** ........................................................ ១៧

៦.១- ការបង្កើតយន្តការសហការ សម្របសម្រួល និងអនុវត្ត ........................................................ ១៧

៦.២- កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ ........................................................ ១៧

៦.៣- ការពង្រឹងក្របខណ្ឌគតិយុត្ត ........................................................ ១៨

៦.៤- ការគាំទ្រហិរញ្ញវត្ថុ ........................................................ ១៨

៦.៥- ការបណ្តុះបណ្តាលធនធានមនុស្ស ............................................................ ១៨
៦.៦- ដំណើរការអនុវត្តគម្រោង ............................................................ ១៩
**៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ** ............................................................ ១៩
**៨- សន្និដ្ឋាន** ............................................................ ២០
**ឧបសម្ព័ន្ធ១ : តារាងសកម្មភាពអាទិភាពនៃគោលនយោបាយ** ............................................................ ២២
**ឧបសម្ព័ន្ធ២ : គំនូសបំព្រួញស្តីពីគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០** ............................................................ ២៩
**ឧបសម្ព័ន្ធ៣ : លំដាប់លេខរៀងនៃសន្ទស្សន៍សម្រាប់ការអភិវឌ្ឍប្រៃសណីយ៍ ២០២១ នៅតាមបណ្តាប្រទេស អាស៊ាន** ............................................................ ៣០
**ឧបសម្ព័ន្ធ៤ : សទ្ទានុក្រម** ............................................................ ៣១

# បញ្ជីពាក្យកាត់

| | |
|---|---|
| ប.ក. | ប្រៃសណីយ៍កម្ពុជា |
| APPU | សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (Asian-Pacific Postal Union) |
| CADT | បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (Cambodia Academy of Digital Technology) |
| CP | ប្រៃសណីយ៍កម្ពុជា (Cambodia Post) |
| EMS | សេវាបញ្ញើប្រៃសណីយ៍ឆាប់រហ័ស (Express Mail Service) |
| IATA | សមាគមដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ (International Air Transport Association) |
| ICAO | អង្គការអាកាសចរស៊ីវិលអន្តរជាតិ (International Civil Aviation Organization) |
| ICT | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (Information and Communication Technology) |
| IPS | ប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ (International Postal System) |
| PPP | ភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnership) |
| RCEP | កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (Regional Comprehensive Economic Partnership) |
| UPS | សេវាប្រៃសណីយ៍សកល (Universal Postal Service) |
| UPU | សហភាពប្រៃសណីយ៍សកល (Universal Postal Union) |
| WCO | អង្គការគយពិភពលោក (World Customs Organization) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក (World Trade Organization) |
| 2IPD | សន្ទស្សន៍សម្រាប់ការអភិវឌ្ឍប្រៃសណីយ៍ ( Integrated Index for Postal Development) |

# មុខកថា

ក្នុងរយៈពេលជាងពីទសវត្សរ៍មកនេះ រាជរដ្ឋាភិបាលកម្ពុជាកសាងបានសមិទ្ធផលសំខាន់ៗជាច្រើនសម្រាប់ជាតិមាតុភូមិ ដោយក្នុងនោះធានាបាននូវចីរភាពនៃសន្តិភាព កំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយបរិយាបន្ន ការកាត់បន្ថយភាពក្រីក្រ វឌ្ឍនភាពក្នុងវិស័យសង្គមកិច្ច ពិសេសវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ និងការបង្កើនវិសាលភាព ប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ ផ្អែកលើមូលដ្ឋាននៃសមិទ្ធផលដែលកសាងបាននេះ រាជរដ្ឋាភិបាលប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការបន្តអនុវត្តឱ្យសម្រេចបានវឌ្ឍនភាពបន្ថែមទៀតក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរបៀបវារៈគោលនយោបាយដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដំណាក់កាលទី៤ នៃរដ្ឋសភា បើទោះបីកម្ពុជាស្ថិតក្នុងកាលៈទេសៈនៃបរិបទនៃជំងឺរាតត្បាតកូវីដ-១៩ ដែលនៅដាក់សម្ពាធមកលើសុខភាពសាធារណៈ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក៏ដោយ។

ក្នុងបរិការណ៍នៃកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍ ដែលកម្ពុជាអាចទទួលបានពីការរីកចម្រើននៃបច្ចេកវិទ្យា និងការវិវត្តផ្នែកសង្គម-សេដ្ឋកិច្ច រាជរដ្ឋាភិបាលបន្តជំរុញការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីពង្រឹង និងពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ច និងបង្កើនភាពធន់ទៅនឹងវិបត្តិ ឈានទៅកសាងបាននូវមូលដ្ឋានគាំទ្ររឹងមាំ សម្រាប់ការសម្រេចចក្ខុវិស័យ ក្នុងការប្រែក្លាយកម្ពុជាជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តរៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យអាទិភាព ដែលមានសក្តានុពលជួយទ្រទ្រង់កំណើនសេដ្ឋកិច្ច ដើម្បីជាត្រីវិស័យសម្រាប់តម្រែតម្រង់ការអនុវត្តផែនការសកម្មភាពរបស់តួអង្គពាក់ព័ន្ធទាំងអស់។

ដោយមើលឃើញពីសក្តានុពលនៃការអភិវឌ្ឍវិស័យប្រៃសណីយ៍ អាស្រ័យដោយមានលក្ខខណ្ឌអនុគ្រោះនិងជំរុញ ដែលកំពុងកើតមានឡើង រាជរដ្ឋាភិបាលសម្រេចដាក់ចេញគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ នេះ ជាមួយនឹងចក្ខុវិស័យនៃការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍ ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជន ប្រកបដោយនវានុវត្តន៍ ប្រសិទ្ធភាព និងនិរន្តរភាព សំដៅចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ការដាក់ចេញគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ក៏ជាការឆ្លើយតបទៅនឹងការកំណត់សកម្មភាពអាទិភាព ដែលត្រូវអនុវត្តក្នុងឯកសារគោលនយោបាយ រដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ដើម្បីសម្រេចបាននូវគោលដៅជាយុទ្ធសាស្ត្រ ស្តីពីការកសាងអភិបាលកិច្ច និងសេវាសាធារណៈឌីជីថល។ ផ្អែកតាមទិសដៅនេះ ការរៀបចំគោលនយោបាយនេះ គឺមានគោលបំណងចាប់យកកាលានុវត្តភាពជាអតិបរមា ក្នុងការជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍ឱ្យកាន់តែមានសន្ទុះ តាមរយៈការធ្វើទំនើបកម្មសេវាប្រៃសណីយ៍ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាស្នូល និងជំរុញការអភិវឌ្ឍក្របខណ្ឌគតិយុត្ត យន្តការ ហេដ្ឋារចនាសម្ព័ន្ធបណ្តាញប្រៃសណីយ៍ ព្រមទាំងការគ្រប់គ្រង

ការធ្វើអាជីវកម្មផ្តល់សេវា ក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន ដើម្បីផ្តល់សេវាស្របតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងនិយាមអន្តរជាតិ ក្នុងបរិបទនៃសកលភាវូបនីយកម្ម។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលបានដឹកនាំរៀបចំឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ រហូតសម្រេចបានជោគជ័យ។ ជាមួយនឹងសុទិដ្ឋិនិយមនៃបច្ច័យវិជ្ជមាន ដែលនឹងកើតចេញពីការអនុវត្តគោលនយោបាយនេះ ខ្ញុំសូមលើកទឹកចិត្ត និងជំរុញឱ្យក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ខិតខំសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទទួលបានលទ្ធផលជាផ្លែផ្កា សំដៅបម្រើ និងផ្តល់ផលប្រយោជន៍ជូនប្រជាជនបានយ៉ាងទូលំទូលាយ និងចូលរួមចំណែកក្នុងការពង្រីកមូលដ្ឋានកំណើនសេដ្ឋកិច្ចជាតិ។

ថ្ងៃ សុក្រ ១៤ កើត ខែភទ្របទ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកញ្ញា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# **អារម្ភកថា**

ក្រោយការផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ វិស័យប្រៃសណីយ៍បានឆ្លងកាត់ដំណាក់កាលស្តារ និងអភិវឌ្ឍន៍ជាបន្តបន្ទាប់។ ប៉ុន្តែ ក្នុងដំណើរវិវឌ្ឍន៍នៃវិស័យប្រៃសណីយ៍ នៅពុំទាន់មានក្របខណ្ឌគោលនយោបាយសមស្របនៅឡើយ ដើម្បីឆ្លើយតបទៅនឹងបរិបទនៃការរីកចម្រើននៃបច្ចេកវិទ្យា និងតម្រូវការកើនឡើងលើសេវាប្រៃសណីយ៍ ដែលកើតចេញពីវឌ្ឍនភាពសង្គម-សេដ្ឋកិច្ច និងការអភិវឌ្ឍនៃវិស័យផ្សេងទៀត។ ផ្អែកលើតថភាពនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានបង្កើត និងប្រគល់ភារកិច្ចជូនក្រុមការងារប្រៃសណីយ៍ ដើម្បីសិក្សាកសាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ ដោយមានការប្រជុំពិគ្រោះយោបល់ និងការប្រមូលធាតុចូលពីតួអង្គពាក់ព័ន្ធនានា។

ឯកសារគោលនយោបាយនេះ ត្រូវបានរៀបចំឡើងស្របតាមឆន្ទៈនៃការកែទម្រង់ការងាររបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីគាំទ្រ សម្របសម្រួល និងធ្វើនិយ័តកម្មលើវិស័យប្រៃសណីយ៍ សំដៅលើកកម្ពស់ការគ្រប់គ្រងវិស័យប្រៃសណីយ៍ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងជំរុញការអភិវឌ្ឍទីផ្សារប្រៃសណីយ៍ ដែលមានការចូលរួមផ្តល់សេវាយ៉ាងទូលំទូលាយពីប្រតិបត្តិករជាតិ និងឯកជន ប្រកបដោយគុណភាព និងភាពជឿទុកចិត្ត ព្រមទាំងប្រើបច្ចេកវិទ្យាឌីជីថល សម្រាប់បម្រើសេចក្តីត្រូវការរបស់ក្រសួង-ស្ថាប័ន សហគ្រាសសាធារណៈ សហគ្រាសឯកជន និងប្រជាជនទូទៅ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារប្រៃសណីយ៍ ក្នុងការរៀបចំតាក់តែងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ នេះ ឱ្យចេញជារូបរាងឡើង។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយក-រដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការ ដើម្បីផ្តល់ធាតុចូលដ៏មានតម្លៃ សម្រាប់កែសម្រួលឯកសារគោលនយោបាយនេះឱ្យកាន់តែមានគុណភាព និងគ្រប់ជ្រុងជ្រោយ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ក៏ដូចជាវិស័យឯកជន និងអង្គការអន្តរជាតិនានា ដែលបានចូលរួមបង្ហាញពីចំណាប់អារម្មណ៍ និងផ្តល់ជាមតិយោបល់លើខ្លឹមសារគោលនយោបាយដ៏មានសារៈសំខាន់នេះ។

តាមរយៈឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នឹងបង្កើនកិច្ចសហការជាមួយភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍ សម្រាប់ផលប្រយោជន៍រួមរបស់ជាតិ។

ថ្ងៃ ចន្ទ ៣រោច ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

# ខ្លឹមសារសង្ខេប

វិស័យប្រៃសណីយ៍ ត្រូវបានចាត់ទុកថាមានសក្តានុពល ក្នុងការចូលរួមចំណែកទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយវិស័យនេះនឹងបង្កើតបានហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដែលជួយសម្រួលដល់ដំណើរប្រព្រឹត្តិទៅក្នុងផ្នែកសង្គម-សេដ្ឋកិច្ច។ ទោះជាយ៉ាងនេះក្តី វិសាលភាពនៃការផ្តល់សេវាប្រៃសណីយ៍នៅមិនទាន់បានគ្របដណ្តប់ទូលំទូលាយនៅក្នុងប្រទេសនៅឡើយ អាស្រ័យដោយការអភិវឌ្ឍប្រៃសណីយ៍របស់សហគ្រាសសាធារណៈ «ប្រៃសណីយ៍កម្ពុជា» ដែលជាប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍នៅមានកម្រិត និងស្ថានភាពនៃបណ្តាញប្រៃសណីយ៍នៅមានលក្ខណៈតូចចង្អៀត ហើយម្យ៉ាងវិញទៀតការធ្វើអាជីវកម្មផ្តល់សេវារបស់ផ្នែកឯកជនក្នុងវិស័យប្រៃសណីយ៍ ក៏ពុំទាន់ត្រូវបានគ្រប់គ្រងបានល្អប្រសើរ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសមត្ថកិច្ចក្នុងការគ្រប់គ្រងលើការធ្វើអាជីវកម្មផ្តល់សេវាប្រៃសណីយ៍ ដែលរួមមានសេវាប្រៃសណីយ៍បែបប្រពៃណី និងសេវាឆាប់រហ័ស ក្នុងនោះគ្របដណ្តប់លើសេវាបញ្ញើប្រៃសណីយ៍ឆាប់រហ័ស (Express Mail Service - EMS) ដែលផ្តល់ដោយប្រតិបត្តិករជាតិ និងសេវាបញ្ញើឆាប់រហ័ស (Courier Service) ដែលផ្តល់ដោយប្រតិបត្តិករឯកជន។

ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច និងទំនោរកើនឡើងនៃការធ្វើប្រតិបត្តិការទិញលក់ទំនិញ និងសេវាតាមប្រព័ន្ធអេឡិចត្រូនិក ទន្ទឹមនឹងការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិត ចំនួនអ្នកប្រើប្រាស់បណ្តាញសង្គម និងសេវាហិរញ្ញវត្ថុតាមប្រព័ន្ធអេឡិចត្រូនិក វឌ្ឍនភាពនៃវិស័យផ្សេងទៀត និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តតភ្ជាប់ក្នុងប្រទេស បានបង្កើតកាលានុវត្តភាពសម្រាប់ទីផ្សារសេវាប្រៃសណីយ៍ និងជាបណ្តាលក្ខខណ្ឌ និងកត្តាអំណោយផល សម្រាប់ជំរុញការអភិវឌ្ឍវិស័យប្រៃសណីយ៍នៅកម្ពុជា។ ប៉ុន្តែ ជាមួយនឹងកាលានុវត្តភាពនេះ ការអភិវឌ្ឍវិស័យប្រៃសណីយ៍នៅជួបប្រទះបញ្ហាប្រឈម ជាអាទិ៍៖ ការខ្វះខាតបទដ្ឋានគតិយុត្ត ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ បណ្តាញប្រៃសណីយ៍ ការធ្វើពិពិធកម្ម និងទំនើបកម្មសេវា យន្តការគ្រប់គ្រងការធ្វើអាជីវកម្មរបស់ផ្នែកឯកជន យន្តការលើកកម្ពស់គុណភាព នៃការផ្តល់សេវាប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថល ក្នុងវិស័យប្រៃសណីយ៍។

ក្នុងបរិការណ៍នេះ ការកសាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ គឺជាប្រទីបនាំផ្លូវឆ្ពោះទៅរកការដោះស្រាយបញ្ហាប្រឈមក្នុងទិសដៅទាញយកផលប្រយោជន៍ពីកាលានុវត្តភាពដែលបាន និងកំពុងលេចឡើង។ គោលនយោបាយនេះ គឺជាឧបករណ៍ដែលបម្រើឱ្យការដោះស្រាយបញ្ហាបណ្តាញតូចចង្អៀត និងភាពមានកម្រិតនៃការផ្តល់សេវាប្រៃសណីយ៍ក្នុងប្រទេសកម្ពុជា សំដៅធ្វើឱ្យការផ្តល់សេវានេះមានលក្ខណៈទូលំទូលាយ មានគុណភាព និងប្រសិទ្ធភាព និងឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការលើសេវាប្រៃសណីយ៍ និងនិន្នាការបច្ចេកវិទ្យា ដែលកំពុងវិវឌ្ឍឥតឈប់ឈរ និងឆាប់រហ័ស។

ចក្ខុវិស័យនៃគោលនយោបាយនេះ គឺ «ការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍ ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជន ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនវានុវត្តន៍ សំដៅចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ»។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ គោលនយោបាយអភិវឌ្ឍន៍វិស័យ

ប្រៃសណីយ៍ ២០២២-២០៣០ បានដាក់ចេញយុទ្ធសាស្ត្រចំនួន៨ គឺ៖ (១) ពង្រឹងក្របខណ្ឌគតិយុត្ត ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ (២) បង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ (៣) លើកកម្ពស់សុវត្ថិភាពការងារ និងចីរភាពបរិស្ថានក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍ (៤) អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញកស្តុភារកម្មប្រៃសណីយ៍ និងជំរុញការធ្វើបរិវត្តកម្មឌីជីថលលើប្រព័ន្ធអេកូឡូហ្ស៊ីប្រៃសណីយ៍សេវាកម្ម និងបណ្តាញប្រៃសណីយ៍ (៥) គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន (៦) ជំរុញការបង្កើនសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជា ក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម (៧) បង្កើតកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល និងចូលរួមគាំទ្រផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល និង (៨) ជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ ក្នុងវិស័យប្រៃសណីយ៍។ ក្រោមយុទ្ធសាស្ត្រនីមួយៗ មានសកម្មភាពអាទិភាពដែលជាគម្រោងត្រូវអនុវត្តក្នុងរយៈពេលពីឆ្នាំ ២០២២ ដល់ឆ្នាំ ២០៣០។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលទទួលបន្ទុកជាសេនាធិការផ្ទាល់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងវិស័យប្រៃសណីយ៍ នឹងពង្រឹងកិច្ចសហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ដើម្បីអនុវត្តសកម្មភាពអាទិភាពឱ្យសម្រេចបានតាមយុទ្ធសាស្ត្រខាងលើ។ ឆន្ទៈនយោបាយ និងការចូលរួមរបស់ភាគីពាក់ព័ន្ធ គឺជាកត្តាកំណត់ដ៏សំខាន់។ ដូច្នេះ ការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ននឹងត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាការចូលរួមរបស់ភាគីពាក់ព័ន្ធជាមួយនឹងការអនុវត្តតួនាទី ប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់ធនធានចាំបាច់ ប្រកបដោយប្រសិទ្ធផល។

ការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានប្រៃសណីយ៍ ដែលមានសមត្ថកិច្ចជាសេនាធិការរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ នឹងត្រូវធ្វើការកែសម្រួលឡើងវិញដើម្បីកំណត់តួនាទី និងភារកិច្ចឱ្យឆ្លើយតបទៅនឹងដំណើរការនៃការអភិវឌ្ឍវិស័យប្រៃសណីយ៍ដូចដែលបានគូសវាស និងត្រួសត្រាយផ្លូវ ដោយគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍នេះ។ ព្រមជាមួយគ្នានេះ ការកសាងសមត្ថភាពរបស់មន្ត្រីគ្រប់ជាន់ថ្នាក់ នឹងត្រូវបានពង្រឹង តាមរយៈការរៀបចំផែនការបណ្តុះបណ្តាលដោយផ្សារភ្ជាប់ជាមួយគោលគំនិតនៃការអភិវឌ្ឍក្នុងយុគសម័យឌីជីថល លើផ្នែកបច្ចេកទេស និងអភិបាលកិច្ចពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍។

គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ នឹងត្រូវអនុវត្តក្រោមប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោយមានការកំណត់សូចនាករគោលដៅដែលអាចវាស់វែងបាន ហើយគោលនយោបាយនេះនឹងត្រូវពិនិត្យមើលឡើងវិញ ដើម្បីពិនិត្យលទ្ធភាពនៃការធ្វើបច្ចុប្បន្នកម្ម និងអនុវត្តបន្ត។

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវបានរំពឹងទុកថានឹងបំពេញតួនាទីគាំទ្រ និងសម្របសម្រួលប្រកបដោយស្មារតីម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ ដើម្បីជំរុញការអនុវត្តរាល់សកម្មភាពដែលបានកំណត់ក្នុងឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ នេះ ឱ្យទទួលបានជោគជ័យ។

## ១- សេចក្តីផ្តើម

ចាប់តាំងពីឆ្នាំ១៩៩៨ តាមរយៈនយោបាយឈ្នះ-ឈ្នះ ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញ ដែលបង្កលក្ខណៈអំណោយផល ដល់កម្ពុជាក្នុងការដាក់ចេញ និងអនុវត្តបានជោគជ័យជាបន្តបន្ទាប់នូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗ សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍជាតិ។ ជាលទ្ធផល ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនប្រចាំឆ្នាំជាមធ្យម ៧% មុនការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យកម្ពុជាផ្លាស់ប្តូរពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥។ ដើម្បីបន្តធានាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព ដែលមានលក្ខណៈបរិយាបន្ន រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា បានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដោយកំណត់ការធ្វើពិពិធកម្មសេដ្ឋកិច្ច ដែលផ្តោតលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ចគន្លឹះថ្មីៗ ការបង្កើត និងការបង្កើនតម្លៃបន្ថែមក្នុងវិស័យដែលមានស្រាប់ ជាដំណើរការចាំបាច់សម្រាប់បង្កើតចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចឱ្យបានច្រើន។ ក្នុងនោះ វិស័យប្រៃសណីយ៍នៃព្រះរាជាណាចក្រកម្ពុជាត្រូវបានចាត់ទុកថាមានសក្តានុពលក្នុងការចូលរួមចំណែក នៅក្នុងដំណើរការទ្រទ្រង់នេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ការអភិវឌ្ឍវិស័យនេះ កំពុងត្រូវបានជំរុញ ដើម្បីបង្កើនលទ្ធភាពនៃការផ្តល់សេវាប្រៃសណីយ៍ ដែលឆ្លើយតបទៅនឹងការកើនឡើងនៃសេចក្តីត្រូវការ ក្នុងជីវភាពរស់នៅរបស់ប្រជាជន និងវឌ្ឍនភាពនៃវិស័យផ្សេងៗក្នុងប្រទេស។

ក្នុងបរិបទនេះ ការកសាងគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ គឺពិតជាតម្រូវការចាំបាច់ និងជាឧបករណ៍មានសារៈសំខាន់បម្រើឱ្យការដោះស្រាយបញ្ហាប្រឈម ដែលជាឧបសគ្គដល់ការសម្រេចបាននូវការអភិវឌ្ឍវិស័យប្រៃសណីយ៍ ការពង្រីកវិសាលភាពសេវាប្រៃសណីយ៍ ដែលមានគុណភាព និងប្រសិទ្ធភាពជូនអ្នកប្រើប្រាស់ ជាពិសេសការបំពេញបាននូវកាតព្វកិច្ចក្នុងការផ្តល់សេវាប្រៃសណីយ៍សកល (Universal Postal Service – UPS) នៅកម្ពុជា។ ក្នុងន័យនេះ ឯកសារគោលនយោបាយនេះនឹងជួយជំរុញ និងតម្រង់ទិសនៃការអភិវឌ្ឍក្របខណ្ឌគតិយុត្ត យន្តការ ហេដ្ឋារចនាសម្ព័ន្ធ បណ្តាញ និងសេវាប្រៃសណីយ៍ ព្រមទាំងពង្រឹងការគ្រប់គ្រងក្នុងវិស័យប្រៃសណីយ៍ ជាមួយនឹងការដាក់ចេញនូវផែនការសកម្មភាពសម្រាប់អនុវត្តជាក់ស្តែង ដែលមានលក្ខណៈប្រទាក់ក្រឡា និងបំពេញឱ្យគ្នាទៅវិញទៅមក សំដៅកសាងភាពធន់នៃវិស័យប្រៃសណីយ៍ ដែលអាចផ្តល់សេវា ប្រកបដោយនិរន្តរភាព ទូលំទូលាយ អាចជឿទុកចិត្តបាន ស្របតាមនិយាមអន្តរជាតិ បំពេញបានតាមតម្រូវការរបស់អ្នកប្រើប្រាស់ និងជួយសម្រួលដល់ការតភ្ជាប់ចុងម្ខាងនៃផលិតកម្មទៅចុងម្ខាងនៃការប្រើប្រាស់។

ដើម្បីធានាប្រសិទ្ធភាព និងភាពឆ្លើយតប គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ ត្រូវបានរៀបចំឱ្យមានសង្គតិភាពទៅនឹងឯកសារសំខាន់ៗ ជាអាទិ៍៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០២០ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

អនុសញ្ញាប្រៃសណីយ៍សកល (Universal Postal Convention) និងយុទ្ធសាស្ត្រប្រៃសណីយ៍របស់សហភាពប្រៃសណីយ៍សកល ព្រមទាំងស្របទៅតាមនិន្នាការប្រែប្រួលនៃបច្ចេកវិទ្យា និងបរិបទឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាការចូលរួមគាំទ្រការកៀរគរ និងការបង្កើនចំណូលចូលថវិកាជាតិ។ ឯកសារគោលនយោបាយនេះចាត់ទុកប្រព័ន្ធប្រៃសណីយ៍ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រ គឺជាផ្នែកដ៏សំខាន់មួយនៃប្រព័ន្ធឡូជីស្ទីក និងការដឹកជញ្ជូនគោលដៅចុងក្រោយ និងការគាំទ្រដល់បរិវត្តកម្មឌីជីថល ដូចការកំណត់នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥។

## ២- ស្ថានភាពវិស័យប្រៃសណីយ៍នៅកម្ពុជា

### ២.១- ដំណើរវិវត្ត

វិស័យប្រៃសណីយ៍នៅកម្ពុជាត្រូវបានបំផ្លាញទាំងស្រុងក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ក្រោយការផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ស្តារវិស័យនេះឡើងវិញ ដោយប្រមែប្រមូលធនធានមនុស្សដែលមានចំណេះដឹង និងបទពិសោធលើវិស័យប្រៃសណីយ៍ បណ្តុះបណ្តាលបច្ចេកទេស រៀបចំបង្កើតបណ្តាញប្រៃសណីយ៍ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។ សាលាប្រៃសណីយ៍និងទូរគមនាគមន៍ជាតិ (Ecole Nationale des Postes et Telecommunications - ENAPOSTEL) ត្រូវបានបង្កើតឡើង ក្នុងដំណាក់កាលស្តារឡើងវិញ ដើម្បីផ្តល់ការបណ្តុះបណ្តាល និងកសាងសមត្ថភាពដល់មន្ត្រី ដែលបម្រើការងារនៅតាមការិយាល័យក្នុងខេត្ត-ក្រុងនានា ដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការអនុវត្តសេវាប្រៃសណីយ៍។ នៅឆ្នាំ១៩៨៧ បទដ្ឋានសេវាប្រៃសណីយ៍ក្នុងនិងក្រៅប្រទេស ត្រូវបានរៀបចំចងក្រង និងដាក់ឱ្យប្រើប្រាស់ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការណែនាំ និងការអនុវត្ត ក្នុងក្របខណ្ឌទូទាំងប្រទេស ឱ្យមានលក្ខណៈស៊ីចង្វាក់គ្នា។ បទដ្ឋាននេះទោះបីនៅមានការខ្វះចន្លោះ និងពុំទាន់មានលក្ខណៈត្រឹមត្រូវល្អឥតខ្ចោះក៏ដោយ ក៏ជាមូលដ្ឋានបច្ចេកទេសសម្រាប់អនុវត្តសេវាប្រៃសណីយ៍ និងផ្តល់នូវក្បួនច្បាប់ជាភាសាជាតិសម្រាប់អនុវត្តចាប់តាំងពីពេលនោះមក។

ចាប់ពីទសវត្សរ៍៩០មក ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលពីមុនមានឈ្មោះថាក្រសួងគមនាគមន៍ ដឹកជញ្ជូន និងប្រៃសណីយ៍ បានផ្តល់សេវាប្រៃសណីយ៍ទាំងក្នុង និងក្រៅប្រទេស។ ទន្ទឹមនឹងនេះ ការចែកបញ្ញើក្នុងស្រុក ក៏កើតមានផងដែរ ក្នុងរូបភាពជាការចែកបញ្ញើតាមរថយន្តតាក់ស៊ី ឬរថយន្តក្រុងដែលដឹកអ្នកដំណើរពីតំបន់មួយទៅតំបន់មួយ។ នៅមុនឆ្នាំ១៩៩៣ មានតែក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍តែមួយប៉ុណ្ណោះ ដែលបានផ្តល់សេវាបញ្ញើប្រៃសណីយ៍អន្តរជាតិ។ លុះក្រោយឆ្នាំ១៩៩៣ ទើបមានក្រុមហ៊ុនឯកជនជាបន្តបន្ទាប់បានចូលរួមផ្តល់សេវាបញ្ញើអន្តរជាតិ។ ជាពិសេស ចាប់តាំងពីមានច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ក្រុមហ៊ុនឯកជនកាន់តែច្រើន បានចាប់ផ្តើមផ្តល់សេវាបញ្ញើឆាប់រហ័ស។

ក្នុងឆ្នាំ២០០២ ច្បាប់ស្តីពីវិស័យប្រៃសណីយ៍ត្រូវបានដាក់ឱ្យប្រើប្រាស់ ដើម្បីគ្រប់គ្រងការងារសេវាកម្មអាជីវកម្មប្រៃសណីយ៍។ ច្បាប់នេះក៏បានផ្តល់សិទ្ធិដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងការចេញអាជ្ញាបណ្ណឱ្យផ្នែកឯកជនធ្វើអាជីវកម្មខាងវិស័យប្រៃសណីយ៍ ដើម្បីជួយបំពេញ និងទ្រទ្រង់ការផ្តល់សេវាប្រៃសណីយ៍ទាំងអស់ជូនប្រជាជន។ ប៉ុន្តែ បទប្បញ្ញត្តិសម្រាប់ការគ្រប់គ្រង និងផ្តល់អាជ្ញាបណ្ណជូន

ប្រតិបត្តិករឯកជន តាមរយៈការចេញប្រកាសអន្តរក្រសួងនៅឆ្នាំ២០០៦ បានកំណត់វិសាលភាពអនុវត្តតែទៅលើសេវាបញ្ញើឆាប់រហ័សអន្តរជាតិប៉ុណ្ណោះ។ នៅឆ្នាំ២០១០ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យបង្កើតប្រៃសណីយ៍កម្ពុជា (Cambodia Post – CP) ជាសហគ្រាសសាធារណៈ មានលក្ខណៈជាក្រុមហ៊ុនរដ្ឋ និងជាប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍។ នៅឆ្នាំ២០១១ សហគ្រាសប្រៃសណីយ៍កម្ពុជាបានកើតចេញជារូបរាងផ្លូវការ និងខិតខំបំពេញភារកិច្ចតាមការកំណត់របស់អនុក្រឹត្យ។ ក្រៅពីការផ្តល់សេវាដែលមានលក្ខណៈពាណិជ្ជកម្ម ប្រៃសណីយ៍កម្ពុជា ក្នុងឋានៈជាប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍តែមួយគត់ របស់ព្រះរាជាណាចក្រកម្ពុជា ដែលជាចំណែកមួយនៃបណ្តាញប្រៃសណីយ៍ពិភពលោក មានកាតព្វកិច្ចផ្តល់សេវាប្រៃសណីយ៍សកល ដោយមិនផ្តោតលើប្រាក់ចំណេញ ស្របតាមអនុសញ្ញាប្រៃសណីយ៍សកល។

ក្នុងនិន្នាការអន្តរជាតិ ដែលបានកើតឡើង ទីផ្សារប្រៃសណីយ៍ត្រូវបានធ្វើសេរីភាវូបនីយកម្ម ហើយអង្គភាពប្រៃសណីយ៍ក្នុងបណ្តាប្រទេសនានាបានឆ្លងកាត់ការកែទម្រង់ និងការរៀបចំរចនាសម្ព័ន្ធឡើងវិញពិសេសក្នុងរយៈពេល ២៥ឆ្នាំ ចុងក្រោយនេះ។ ដូចគ្នានេះដែរ វិស័យប្រៃសណីយ៍នៅកម្ពុជាបានវិវត្តស្របតាមនិន្នាការអន្តរជាតិនេះ ហើយរហូតមកដល់ពេលនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍គ្រប់គ្រងលើការធ្វើអាជីវកម្មផ្តល់សេវាប្រៃសណីយ៍ ដែលរួមមានសេវាប្រៃសណីយ៍បែបប្រពៃណី និងសេវាឆាប់រហ័សក្នុងនោះគ្របដណ្តប់លើសេវាបញ្ញើប្រៃសណីយ៍ឆាប់រហ័ស (Express Mail Service - EMS) ដែលផ្តល់ដោយប្រតិបត្តិករជាតិ និងសេវាបញ្ញើឆាប់រហ័ស (Courier Service) ដែលផ្តល់ដោយប្រតិបត្តិករឯកជន។

ត្រឹមខែកក្កដា ឆ្នាំ២០២២ ប្រៃសណីយ៍កម្ពុជាមានសាខាចំនួន ៤៤ និងធ្វើអាជីវកម្មប្រកួតប្រជែងជាមួយក្រុមហ៊ុនចុះបញ្ជីបម្រើសេវាបញ្ញើឆាប់រហ័សចំនួន ៦១ ក្រុមហ៊ុន ដែលមានសាខាចុះបញ្ជីនៅទូទាំងប្រទេសសរុបចំនួន ១៦៧ សាខា។ ប្រៃសណីយ៍កម្ពុជាដែលជាប្រតិបត្តិករជាតិមាននិយោជិតបម្រើការងារចំនួន ៤៦២ នាក់។ ក្នុងចន្លោះពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ប្រៃសណីយ៍កម្ពុជាមានបរិមាណបញ្ញើជាមធ្យម ១,២ លានឯកតាបញ្ញើក្នុងមួយឆ្នាំ ដែលបរិមាណនេះតំណាងឱ្យតែ ១% នៃទំហំទីផ្សារដែលមាននៅក្នុងប្រទេសកម្ពុជាប្រមាណ ១០០ លានឯកតាបញ្ញើ។ ម្យ៉ាងវិញទៀត ៩៧% នៃបរិមាណបញ្ញើរបស់ប្រៃសណីយ៍កម្ពុជា គឺពឹងផ្អែកទៅលើបញ្ញើអន្តរជាតិ ទាំងបញ្ញើចេញ ទាំងបញ្ញើចូល។ ប្រៃសណីយ៍កម្ពុជាពុំមានសកម្មភាពខ្លាំងក្លា ក្នុងការផ្តល់សេវាបញ្ញើប្រៃសណីយ៍ក្នុងស្រុក ខណៈដែលការអភិវឌ្ឍប្រៃសណីយ៍នៅមានកម្រិតទាប បើធៀបទៅនឹងបណ្តាប្រទេសភាគច្រើនក្នុងតំបន់។ យោងតាមសន្ទស្សន៍សម្រាប់ការអភិវឌ្ឍប្រៃសណីយ៍ (Integrated Index for Postal Development – 2IPD) ឆ្នាំ២០២១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៣ ដែលបានបង្ហាញក្នុងរបាយការណ៍ ស្តីពីការអភិវឌ្ឍប្រៃសណីយ៍ឆ្នាំ២០២១ របស់សហភាពប្រៃសណីយ៍សកល កម្ពុជាឈរនៅលេខរៀងទី៨៤ ដែលមាន ២៨,៦៨ពិន្ទុ ក្នុងចំណោមប្រទេសចំនួន ១៦៨ បើប្រៀបធៀបទៅនឹងប្រទេសសិង្ហបុរី ដែលឈរនៅលេខរៀងទី១០ មាន ៧៧,១ពិន្ទុ ថៃនៅលេខរៀងទី៣០ មាន ៥៩ពិន្ទុ ឬ វៀតណាមនៅលេខរៀងទី៤៧ មាន ៤៨ពិន្ទុ។ ដូច្នេះ វិសាលភាពនៃការផ្តល់សេវាប្រៃសណីយ៍របស់ប្រតិបត្តិករជាតិនេះ នៅមិនទាន់បានគ្របដណ្តប់ទូលំទូលាយនៅគ្រប់ភូមិសាស្ត្រនៃប្រទេស ព្រមទាំងងាយទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ ហើយប្រភពទទួលបានចំណូលនៅមានលក្ខណៈតូចចង្អៀត។

ការចាប់យកបច្ចេកវិទ្យាឌីជីថលក្នុងពិភពលោក កំពុងតែស្ថិតក្នុងល្បឿនមួយយ៉ាងលឿន។ ដូច្នេះ ការប្រើប្រាស់សេវាប្រៃសណីយ៍តាមប្រព័ន្ធឌីជីថល ក៏ត្រូវបានរំពឹងថានឹងកើនឡើងយ៉ាងខ្លាំង។ ការណ៍នេះ បានជំរុញ និងទាក់ទាញឱ្យបណ្ដាប្រតិបត្តិករប្រៃសណីយ៍ក្នុងប្រទេសនានា បង្កើនការវិនិយោគលើសេវាប្រៃសណីយ៍ឌីជីថល ដើម្បីអាចប្រកួតប្រជែង ប្រកបដោយប្រសិទ្ធភាពក្នុងទីផ្សារ។ ទោះជាយ៉ាងនេះក្ដី ប្រៃសណីយ៍កម្ពុជា ដែលជាប្រតិបត្តិករជាតិ ស្ថិតនៅក្នុងកម្រិតទាបនៅឡើយ ក្នុងការផ្ដល់សេវាប្រៃសណីយ៍តាមប្រព័ន្ធអេឡិចត្រូនិក បើធៀបទៅនឹងប្រទេសផ្សេងក្នុងពិភពលោក។ យោងតាមសន្ទស្សន៍សមត្ថភាពសេវាប្រៃសណីយ៍ឌីជីថល (Digital Postal Services Capacity Index) លើផ្នែកសន្ទស្សន៍ប្រៃសណីយ៍ និងរដ្ឋាភិបាលតាមប្រព័ន្ធអេឡិចត្រូនិក ដែលបានបង្ហាញក្នុងរបាយការណ៍ឆ្នាំ២០១៩ ស្ដីពីសកម្មភាពប្រៃសណីយ៍ឌីជីថល និងសេដ្ឋកិច្ចឌីជីថលរបស់សហភាពប្រៃសណីយ៍សកល ប្រៃសណីយ៍កម្ពុជាឈរនៅលំដាប់លេខរៀងទី ១១១ ប៉ុណ្ណោះ ក្នុងចំណោមប្រតិបត្តិករប្រៃសណីយ៍ នៃប្រទេសចំនួន១២៥។ សហភាពប្រៃសណីយ៍សកលបានរកឃើញថា មានកត្តាគន្លឹះ៤ ដែលជួយធានាឱ្យប្រតិបត្តិករផ្ដល់សេវាប្រៃសណីយ៍ ប្រកបដោយនិរន្តរភាព ក្នុងនោះរួមមាន ៖ ការបង្កលក្ខណៈឱ្យបណ្ដាសាខាអាចមានលទ្ធភាពផ្ដល់សេវាឌីជីថលក្នុងបណ្ដាញរបស់ខ្លួន, ការទទួលបានហិរញ្ញប្បទាន សម្រាប់អនុវត្តគម្រោងឌីជីថល, ការបង្កើតភាពជាដៃគូជាមួយបណ្ដាប្រតិបត្តិករផ្សេងទៀត ដើម្បីចែករំលែកហានិភ័យ និងកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ, និងការផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រឌីជីថលរបស់រដ្ឋាភិបាល។ ក្នុងន័យនេះ ប្រតិបត្តិករជាតិកម្ពុជាចាំបាច់ត្រូវគិតគូរដល់កត្តាទាំង៤ នៃឧត្តមានុវត្តន៍នេះ និងបង្កើនល្បឿនចាប់យកបច្ចេកវិទ្យាឌីជីថល ដើរឱ្យទាន់ការវិវឌ្ឍនៃការផ្ដល់សេវាក្នុងទីផ្សារសេវាប្រៃសណីយ៍។

ក្រៅពីប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន ដែលមានអាជ្ញាបណ្ណផ្ដល់សេវា ក៏នៅមានក្រុមហ៊ុនដែលកំពុងផ្ដល់សេវាប្រៃសណីយ៍ តែពុំបានស្នើសុំអាជ្ញាបណ្ណ។ សេវាបែបនេះ ធ្វើឱ្យអ្នកប្រើប្រាស់ត្រូវទទួលរងនូវការកំណត់ថ្លៃ ដែលមានភាពមិនទៀងទាត់ និងត្រូវប្រឈមនឹងហានិភ័យនៃការយឺតយ៉ាវ បាត់បង់ និងខូចខាតបញ្ញើរបស់ខ្លួន ព្រមទាំងអាចប៉ះពាល់ដល់សុវត្ថិភាព និងសន្តិសុខសាធារណៈ។

## ២.២- កត្តាអំណោយផល និងបញ្ហាប្រឈម

ការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងការរីកចម្រើននៃសង្គម-សេដ្ឋកិច្ច និងវប្បធម៌ បានធ្វើឱ្យមានការផ្លាស់ប្ដូររបៀបរបបរស់នៅ ជាពិសេស មធ្យោបាយក្នុងការធ្វើទំនាក់ទំនង ដូចជាបញ្ញើប្រៃសណីយ៍ ជាសំបុត្រ លិខិត ឯកសារ ជាដើម ដែលត្រូវទទួលរងផលប៉ះពាល់យ៉ាងខ្លាំង។ ប៉ុន្តែផ្ទុយទៅវិញ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បញ្ញើប្រៃសណីយ៍កញ្ចប់តូច និងប្រៃសណីយភណ្ឌ នៅតែជាសេវាប្រកបដោយសក្ដានុពល អាស្រ័យដោយមានការពេញនិយមកាន់តែខ្លាំងឡើង លើការទិញលក់ផលិតផលតាមអនឡាញ ដែលជាការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ទូរស័ព្ទត្រូវបានប្រើប្រាស់ មិនមែនគ្រាន់តែបម្រើឱ្យការសន្ទនាប៉ុណ្ណោះទេ តែជាមធ្យោបាយទំនាក់ទំនងបែបថ្មី សម្រាប់ជ្រើសរើសប្រភេទទំនិញទូទាត់ប្រាក់ ជ្រើសរើសវិធីសាស្ត្រនិងភ្នាក់ងារបញ្ជូនទំនិញ ព្រមទាំងទីកន្លែង និងពេលវេលានៃការប្រគល់ និងទទួលទំនិញ។ ប្រជាជនកម្ពុជាកំពុងមានទំនោរទៅរកការបញ្ជាទិញនៅលើកញ្ចក់ទូរស័ព្ទ ឬឧបករណ៍អេឡិចត្រូនិកឆ្លាត

របស់ខ្លួន ដោយគ្រាន់តែចុចមួយឃ្លីក អាចទទួលបានទំនិញដែលខ្លួនត្រូវការ។ ក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល វិស័យប្រៃសណីយ៍អាចមានសក្តានុពល ក្នុងការបំពេញតួនាទីគាំទ្រដល់ដំណើរវិវឌ្ឍនៃបច្ចេកវិទ្យាដែលមានឥទ្ធិពលធ្វើឱ្យប្រែប្រួលដល់របៀបនៃការធ្វើប្រតិបត្តិការទិញលក់ទំនិញ។

ការកើនឡើងនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទន្ទឹមនឹងការកើនឡើងនៃការប្រើប្រាស់អ៊ីនធឺណិតដែលមានតម្លៃសមរម្យ និងចំនួននៃអ្នកប្រើប្រាស់បណ្តាញសង្គម បង្កើតនូវកាលានុវត្តភាពសម្រាប់ទីផ្សារសេវាប្រៃសណីយ៍។ សកម្មភាពអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិកមានការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងប្រព័ន្ធអេកូឡូហ្ស៊ីនៃពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងនោះក៏មានប្រព័ន្ធទូទាត់ប្រាក់តាមទូរស័ព្ទចល័តផងដែរ។ ជាមួយគ្នានេះ សកម្មភាពអាជីវកម្មតាមបណ្តាញសង្គម ពិសេសសហគ្រិនខ្នាតតូចដែលធ្វើអាជីវកម្មជាលក្ខណៈអតិថិជនទៅអតិថិជនក៏កំពុងរីកលូតលាស់យ៉ាងឆាប់រហ័ស។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកត្រូវបានគាំទ្រដោយច្បាប់ លិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ និងផែនការយុទ្ធសាស្ត្រច្បាស់លាស់ ដែលរួមមាន៖ ច្បាប់ស្តីពីពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដែលបានអនុម័តនៅឆ្នាំ២០១៩ យុទ្ធសាស្ត្រពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិកឆ្នាំ២០២០ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៩-២០២៣ ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២១-២០៣៥។ ម្យ៉ាងវិញទៀត ក្នុងក្របខណ្ឌតំបន់ និងពិភពលោក ប្រទេសកម្ពុជាក៏ជាហត្ថលេខីក្នុងកិច្ចព្រមព្រៀងទាក់ទងនឹងពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក ដែលមានជាអាទិ៍ កិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (ASEAN Agreement on Electronic Commerce) និងកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)។

ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការផ្តល់សេវាបញ្ញើប្រៃសណីយ៍ គឺជាកម្លាំងដែលជំរុញគ្នាទៅវិញទៅមក។ ខណៈដែលពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ជំរុញការអភិវឌ្ឍទីផ្សារសេវាបញ្ញើប្រៃសណីយ៍, ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសអំណោយផលដែលផ្តោតលើការលើកកម្ពស់គុណភាពនិងភាពជឿទុកចិត្ត នៃការផ្តល់សេវាបញ្ញើប្រៃសណីយ៍ សម្រាប់បម្រើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ទាំងក្នុងស្រុក ទាំងឆ្លងកាត់ព្រំដែន រួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើននៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការទាក់ទាញវិនិយោគលើផ្នែកនេះ។ ក្នុងនិន្នាការដូចគ្នានេះដែរ វិស័យប្រៃសណីយ៍ដែលមានទាំងប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន ត្រូវបានជំរុញឱ្យចូលរួមផ្តល់សេវាពាក់ព័ន្ធនានាក្នុងវិស័យនេះ អាចមានសក្តានុពលក្នុងការដើរតួនាទីជាថ្នាលគាំទ្រ ឬកម្លាំងជំរុញការអភិវឌ្ឍវិស័យផ្សេងទៀតដូចជាវិស័យឧស្សាហកម្មជាដើម។

ក្រៅពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលត្រូវបានចាត់ទុកថាមានសក្តានុពលសម្រាប់ជំរុញតម្រូវការលើសេវាប្រៃសណីយ៍នៅកម្ពុជា កម្លាំងពលកម្មដែលផ្លាស់ទីទៅធ្វើការនៅតំបន់ផ្សេងៗក្នុងប្រទេស រួមទាំងកម្លាំងពលកម្មដែលធ្វើការនៅក្រៅប្រទេស ក៏ជាកត្តាមួយទៀតដែលត្រូវបានរំពឹងថានឹងជំរុញតម្រូវការនេះផងដែរ។ លើសពីនេះ សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការធ្វើសមាហរណកម្មផ្ទៃក្នុងប្រទេស តាមរយៈការខិតខំអភិវឌ្ឍបណ្តាញហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ទៅគ្រប់ច្រកល្ហកនៅក្នុងប្រទេស ពិតជា

ជួយសម្រួលដល់ដំណើរការទីផ្សារសេវាប្រៃសណីយ៍នៅកម្ពុជា។ ការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគ្រប់ផ្នែក រួមទាំងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនខ្នាតតូច និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ជនបទ ត្រូវបានកំណត់ច្បាស់លាស់ក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ជាមួយនឹងកាលានុវត្តភាព ដែលបានលេចឡើង និងត្រូវបានឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃបច្ចេកវិទ្យាសង្គម-សេដ្ឋកិច្ច និងវឌ្ឍនភាពនៃវិស័យផ្សេងៗ វិស័យប្រៃសណីយ៍នៅជួបប្រទះបញ្ហាប្រឈមដែលធ្វើឱ្យវិស័យនេះមិនទាន់អាចឆ្លើយតបបានពេញលេញ និងល្អប្រសើរ ទៅនឹងតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់។ ភាពក្រៅផ្លូវការនៃប្រតិបត្តិការផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍នៅកើតមាន ហើយបើទោះ-បីជាមានប្រតិបត្តិការ ដែលបាននិងកំពុងកើតមានក្នុងប្រព័ន្ធផ្លូវការ ក៏ប្រតិបត្តិការទាំងនេះនៅពុំទាន់ត្រូវបានគ្រប់គ្រងល្អប្រសើរ អាស្រ័យដោយយន្តការ និងក្របខណ្ឌគតិយុត្ត នៅពុំទាន់បានអភិវឌ្ឍច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ។ លិខិតបទដ្ឋានគតិយុត្តនៅក្នុងវិស័យប្រៃសណីយ៍ នៅមិនទាន់បានចែងពេញលេញពីការកំណត់បទដ្ឋាន និងបទប្បញ្ញត្តិទាក់ទងនឹងគុណភាព សុវត្ថិភាពទំនិញ និងសេវា និងការការពារអ្នកប្រើប្រាស់។ ក្រៅពីនេះ ក្នុងប្រព័ន្ធប្រៃសណីយ៍ នៅពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធចាំបាច់គ្រប់គ្រាន់ ទាំងហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់ និងផ្នែករឹង ដើម្បីសម្រួលដល់ប្រតិបត្តិការ ដែលបម្រើឱ្យផ្នែកសង្គម-សេដ្ឋកិច្ច។ ម៉្យាងវិញទៀត វិសាលភាពនៃបណ្តាញប្រៃសណីយ៍សម្រាប់ទ្រទ្រង់ការផ្តល់សេវាប្រៃសណីយ៍រហូតដល់គោលដៅចុងក្រោយនៅមានកម្រិត ហើយប្រព័ន្ធឌីជីថលក៏មិនទាន់ត្រូវបានរៀបចំសម្រាប់ផ្សារភ្ជាប់ភាគីពាក់ព័ន្ធនានា ក្នុងប្រព័ន្ធអេកូឡូហ្ស៊ីនៃវិស័យប្រៃសណីយ៍ សម្រាប់ផ្តល់ជម្រើសងាយស្រួលដល់អ្នកប្រើប្រាស់ និងគាំទ្រដល់ប្រតិបត្តិការប្រៃសណីយ៍តាមប្រព័ន្ធអេឡិចត្រូនិក ក្នុងបរិបទនៃសេដ្ឋកិច្ចឌីជីថល។ ជារួម ការខ្វះខាតបទដ្ឋានគតិយុត្ត ហេដ្ឋារចនាសម្ព័ន្ធគាំទ្រ បណ្តាញប្រៃសណីយ៍ ការធ្វើពិពិធកម្ម ទំនើបកម្មសេវា យន្តការគ្រប់គ្រងការធ្វើអាជីវកម្មរបស់ផ្នែកឯកជន យន្តការលើកកម្ពស់គុណភាពនៃការផ្តល់សេវា និងការខ្វះខាតប្រព័ន្ធអេកូឡូហ្ស៊ីឌីជីថលក្នុងវិស័យប្រៃសណីយ៍ ព្រមជាមួយនឹងភាពងាយទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ និងភាពយឺតយ៉ាវនៃការចាប់យកបច្ចេកវិទ្យាដើម្បីបង្កើនប្រសិទ្ធភាពការងារ គឺសុទ្ធតែជាបញ្ហាជាក់ស្តែងចំពោះមុខដែលត្រូវដោះស្រាយ។

ក្នុងបរិការណ៍នេះ គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ គឺជាមូលដ្ឋានគ្រឹះ និងជាត្រីវិស័យនាំផ្លូវឆ្ពោះទៅរកដំណោះស្រាយ ដើម្បីចាប់ឱ្យបាននូវកាលានុវត្តភាព ដែលកើតមានក្នុងការអភិវឌ្ឍវិស័យប្រៃសណីយ៍។ ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ក៏ដូចជាការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថល គោលនយោបាយនេះប្រកាន់យកអភិក្រម **«អភិវឌ្ឍ-ធ្វើបរិវត្តកម្ម-នវានុវត្ត»** ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងនៃវិស័យប្រៃសណីយ៍ សម្រាប់សកម្មភាពវិនិយោគ និងធុរកិច្ចដូចខាងក្រោម៖

- **អភិវឌ្ឍ** : សំដៅរៀបចំក្របខណ្ឌគតិយុត្ត និងអង្គភាពគ្រប់គ្រងនិងសម្របសម្រួល ពិសេសការជំរុញភាពក្រៅផ្លូវការ ទៅជាភាពផ្លូវការ និងការពង្រឹង និងការពង្រីកវិសាលភាពនៃវិស័យប្រៃសណីយ៍។
- **ធ្វើបរិវត្តកម្ម** : សំដៅចាប់យកសក្តានុពលនៃបច្ចេកវិទ្យាដែលបាននិងកំពុងវិវឌ្ឍយ៉ាងឆាប់រហ័ស។

- **នវានុវត្ត** : សំដៅបង្កើនការប្រើប្រាស់សក្តានុពលនៃហេដ្ឋារចនាសម្ព័ន្ធ និង/ឬប្រព័ន្ធប្រៃសណីយ៍ មិនត្រឹមតែជាផ្នែកមួយនៃការផ្តល់សេវាប្រៃសណីយ៍ ប្រព័ន្ធឡជីស្ទីក និងការដឹកជញ្ជូនគោលដៅចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសមាសធាតុចូលរួមដល់វឌ្ឍនភាពសង្គម ប្រកបដោយបរិយាបន្ន និងចីរភាព។

## ៣- ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍ ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជន ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនវានុវត្តន៍ សំដៅចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។

## ៤- គោលបំណង និង គោលដៅ

### ៤.១- គោលបំណង

គោលនយោបាយនេះមានគោលបំណងពង្រឹង និងពង្រីកការផ្តល់សេវាប្រៃសណីយ៍ឱ្យបានទូលំទូលាយ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាព និងភាពជឿទុកចិត្ត ព្រមទាំងគាំទ្រការធ្វើពិពិធកម្មសេវាប្រៃសណីយ៍ និងការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍ ជាមួយនឹងការជំរុញការធ្វើទំនើបកម្ម និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីរួមចំណែកទ្រទ្រង់ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។

### ៤.២- គោលដៅ

ដើម្បីសម្រេចបានចក្ខុវិស័យ និងគោលបំណងខាងលើ គោលនយោបាយនេះកំណត់គោលដៅចំនួន ៤ ដូចខាងក្រោម៖

- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវិស័យប្រៃសណីយ៍ ដើម្បីធានាការលើកកម្ពស់គុណភាពសេវា និងការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់ តាមរយៈការកសាងក្របខណ្ឌគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។
- ធ្វើទំនើបកម្មសេវាប្រៃសណីយ៍ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ពង្រីកបណ្តាញប្រៃសណីយ៍ ឱ្យមានវិសាលភាពទូលំទូលាយ ខិតទៅដល់ប្រជាជន និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល សំដៅគាំទ្រការផ្តល់សេវាប្រៃសណីយ៍ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ និងចូលរួមគាំទ្រដល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងសេវាសាធារណៈរបស់រដ្ឋាភិបាលឌីជីថល។
- បង្កលក្ខណៈងាយស្រួលដល់វិស័យឯកជន ក្នុងការធ្វើអាជីវកម្មក្នុងវិស័យប្រៃសណីយ៍ ដឹកជញ្ជូន និងចែកបញ្ញើប្រៃសណីយ៍ ដោយជំរុញការប្រកួតប្រជែងដោយសុចរិត ក្នុងក្របខណ្ឌគតិយុត្តច្បាស់លាស់ និងការចូលរួមអភិវឌ្ឍឧស្សាហកម្មប្រៃសណីយ៍ ក្រោមរូបភាពនៃការវិនិយោគ

របស់វិនិយោគិនក្នុងស្រុក និងក្រៅប្រទេស និងភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public Private Partnership-PPP)។

- លើកកម្ពស់តួនាទីរបស់ប្រៃសណីយ៍កម្ពុជា ក្នុងការផ្តល់សេវាប្រៃសណីយ៍ ជាមួយនឹងការជំរុញការធ្វើពិពិធកម្មសេវាកម្ម និងផលិតផលប្រៃសណីយ៍ នវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។

## ៥- យុទ្ធសាស្ត្រ

ការអភិវឌ្ឍវិស័យប្រៃសណីយ៍ ត្រូវផ្អែកលើយន្តការដែលមានការផ្សារភ្ជាប់គ្នារវាងគោលនយោបាយ បទដ្ឋានគតិយុត្ត រចនាសម្ព័ន្ធស្ថាប័ន និងប្រតិបត្តិការក្នុងការផ្តល់សេវា ដើម្បីឈានទៅបង្កើតប្រព័ន្ធគាំទ្រដែលមានភាពប្រទាក់ក្រឡាគ្នា សំដៅលើកកម្ពស់ការផ្តល់សេវាប្រៃសណីយ៍ក្នុងបណ្តាញ ដែលមានការតភ្ជាប់គ្នា និងពង្រឹងការគ្រប់គ្រងការធ្វើអាជីវកម្មក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន។ ក្នុងន័យនេះ យន្តការនៃការជំរុញការអភិវឌ្ឍ ត្រូវជួយសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពនវានុវត្តន៍របស់ប្រតិបត្តិករ ដើម្បីធ្វើពិពិធកម្មលើការផ្តល់សេវាបង្កើនចំណូល និងដើម្បីផ្តល់សេវាប្រៃសណីយ៍ ប្រកបដោយបរិយាបន្ន។ យន្តការនេះ ក៏ត្រូវរៀបចំឱ្យមានការធ្វើនិយ័តកម្ម និងការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាពផងដែរ។

ដើម្បីសម្រេចបាននូវគោលដៅ និងគោលបំណង នៃការអភិវឌ្ឍវិស័យប្រៃសណីយ៍ ស្របតាមអភិក្រម **«អភិវឌ្ឍ-ធ្វើបរិវត្តកម្ម-នវានុវត្ត»** យុទ្ធសាស្ត្រសំខាន់ៗត្រូវបានកំណត់ដូចខាងក្រោម៖

### ៥.១- ពង្រឹងក្របខណ្ឌគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍

ការអភិវឌ្ឍវិស័យប្រៃសណីយ៍នៅកម្ពុជា ទាមទារនូវការកសាងក្របខណ្ឌគតិយុត្តរឹងមាំ និងច្បាស់-លាស់ ដែលជាមូលដ្ឋានសំខាន់ និងចាំបាច់ សម្រាប់ការគ្រប់គ្រងវិស័យប្រៃសណីយ៍ ស្របតាមបរិបទនៃការផ្លាស់ប្តូរចរន្តសង្គម-សេដ្ឋកិច្ច និងការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងការបង្កើតបរិយាកាសសមស្របសម្រាប់ការធ្វើអាជីវកម្មសេវាប្រៃសណីយ៍ ដែលបញ្ចៀសបាននូវភាពគ្មានសណ្តាប់ធ្នាប់ និងហានិភ័យនានា ព្រមទាំងកសាងបាននូវជំនឿទុកចិត្តរបស់អ្នកប្រើប្រាស់លើការផ្តល់សេវា។ ក្នុងបរិការណ៍នេះ ត្រូវជំរុញការរៀបចំច្បាប់ស្តីពីសេវាប្រៃសណីយ៍ ជំនួសឱ្យច្បាប់ស្តីពីវិស័យប្រៃសណីយ៍ ដែលត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់នៅឆ្នាំ២០០២ ដែលនៅមានចំណុចខ្វះខាតបទប្បញ្ញត្តិក្នុងការគ្រប់គ្រង និងការឆ្លើយតបទៅនឹងនិន្នាការ និងការវិវត្តនៃទីផ្សារផ្តល់សេវាប្រៃសណីយ៍។ ច្បាប់ស្តីពីសេវាប្រៃសណីយ៍ត្រូវមានខ្លឹមសារជាមូលដ្ឋានដូចខាងក្រោម៖

- មុខងាររបស់ស្ថាប័នមានសមត្ថកិច្ច សមត្ថកិច្ចក្នុងការធ្វើនិយ័តកម្មសេវាប្រៃសណីយ៍ ក្របខណ្ឌអាជ្ញាបណ្ណ ការប្រកួតប្រជែង សិទ្ធិនិងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវានិងអ្នកប្រើប្រាស់ និងកាតព្វកិច្ចសេវាប្រៃសណីយ៍សកល ក្នុងគោលដៅពង្រឹង និងពង្រីកការគ្រប់គ្រងសេវា

ប្រៃសណីយ៍ ធានាបាននូវការអភិវឌ្ឍវិស័យប្រៃសណីយ៍ ប្រកបដោយប្រសិទ្ធភាព និងនវានុវត្តន៍ និងបង្កើនភាពជឿជាក់របស់ប្រជាជនលើការផ្តល់សេវាប្រៃសណីយ៍។

- ការផ្តោតលើក្របខណ្ឌការងារគ្រប់គ្រងការងារសេវាកម្ម និងអាជីវកម្មសេវាប្រៃសណីយ៍គ្រប់ប្រភេទ និងការពិនិត្យតាមដាន ដើម្បីធានាប្រសិទ្ធផលនៃច្បាប់ អាជ្ញាបណ្ណ វិញ្ញាបនបត្រ និងលិខិតអនុញ្ញាត ដែលកំណត់អំពីនីតិវិធី លក្ខខណ្ឌ និងកាតព្វកិច្ចរបស់អ្នកផ្តល់សេវាប្រៃសណីយ៍ ដើម្បីគ្រប់គ្រងការធ្វើអាជីវកម្មសេវាប្រៃសណីយ៍ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព និងដើម្បីធានាសណ្តាប់ធ្នាប់នៃការធ្វើអាជីវកម្ម, ការគ្រប់គ្រងគុណភាពសេវាប្រៃសណីយ៍ ដែលកំណត់អំពីវិធានគ្រប់គ្រងការពង្រឹងគុណភាពសេវា, ការកំណត់និយាមសេវាប្រៃសណីយ៍សកល (UPS), ការផ្តល់ព័ត៌មានគ្រប់គ្រាន់ និងពេញលេញនៃការផ្តល់សេវា ដើម្បីបង្កើនភាពជឿទុកចិត្តដល់អ្នកប្រើប្រាស់លើការផ្តល់សេវា និងសុវត្ថិភាពបញ្ញើប្រៃសណីយ៍, និងការគាំទ្រដល់សេវាអេឡិចត្រូនិក ដែលចាំបាច់ ។ល។

## ៥.២- បង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់

ការអភិវឌ្ឍទីផ្សារប្រៃសណីយ៍ ត្រូវដើរទន្ទឹមគ្នានឹងការធ្វើឱ្យប្រសើរឡើងនូវគុណភាព នៃការផ្តល់សេវា។ ក្នុងន័យនេះ ចាំបាច់ត្រូវមានយន្តការសម្រាប់ការគ្រប់គ្រង និងជំរុញអ្នកផ្តល់សេវាក្នុងការលើកកម្ពស់គុណភាព និងភាពជឿជាក់លើការផ្តល់សេវាប្រៃសណីយ៍ ដើម្បីការពារអ្នកប្រើប្រាស់ និងបំពេញបានតាមក្តីរំពឹងទុកខ្ពស់របស់អ្នកប្រើប្រាស់។ ការងារចាំបាច់ សម្រាប់លើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ មានជាអាទិ៍៖

- ពិនិត្យតាមដានគុណភាពជាប់ជាប្រចាំ នៃការផ្តល់សេវាប្រៃសណីយ៍សកល ឱ្យស្របតាមបទដ្ឋានបច្ចេកទេសជាតិ និងនិយាមដែលបានកំណត់ សំដៅគោរពតាមបទប្បញ្ញត្តិ និងស្តង់ដាបច្ចេកទេស របស់សហភាពប្រៃសណីយ៍សកល ព្រមទាំងពិនិត្យតាមដានគុណភាព នៃការផ្តល់សេវាដែលមានលក្ខណៈពាណិជ្ជកម្មរបស់អ្នកផ្តល់សេវា រួមទាំងប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន។
- រៀបចំបែបបទនៃដំណើរការត្រួតពិនិត្យ និងក្រមសីលធម៌របស់មន្ត្រី ក្នុងការត្រួតពិនិត្យការងារសេវាកម្ម និងអាជីវកម្មប្រៃសណីយ៍។
- បង្កើតប្រព័ន្ធឌីជីថល (ថ្នាល) ដើម្បីត្រួតពិនិត្យតាមដានការគ្រប់គ្រងគុណភាព នៃការផ្តល់សេវាប្រៃសណីយ៍ សំដៅធានាប្រសិទ្ធភាព និងការពារផលប្រយោជន៍របស់អ្នកប្រើប្រាស់។
- វាយតម្លៃពីវឌ្ឍនភាព នៃការផ្តល់សេវាជាក់ស្តែងរបស់អ្នកផ្តល់សេវាប្រៃសណីយ៍ ធៀបនឹងសូចនាករគុណភាពសេវា ដែលបានធ្វើស្វ័យប្រកាស និងផ្សព្វផ្សាយជាសាធារណៈនូវនិយាមនៃការផ្តល់សេវារបស់អ្នកផ្តល់សេវា ដើម្បីបង្កើនភាពជឿជាក់របស់អ្នកប្រើប្រាស់។

- កំណត់លក្ខខណ្ឌអាជ្ញាបណ្ណ ដែលតម្រូវឱ្យប្រតិបត្តិកររៀបចំនីតិវិធីសាមញ្ញ មិនស្មុគស្មាញ សម្រាប់ដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់ ក្នុងករណីមានការបាត់បង់បញ្ញើប្រៃសណីយ៍ ការបែកបាក់ និងការខូចខាតវត្ថុបញ្ញើ ។ល។ ព្រមទាំបង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ា របស់អ្នកប្រើប្រាស់ ដែលមិនបានពេញចិត្តនឹងដំណោះស្រាយរបស់ប្រតិបត្តិករផ្ដល់សេវា។
- ប្រមូលចងក្រងទិន្នន័យ និងកំណត់សូចនាករវាស់វែងសំខាន់ៗ ស្របតាមគោលការណ៍និយាម និងទម្រង់របស់សហភាពប្រៃសណីយ៍សកល ដើម្បីរៀបចំបញ្ចូល ក្នុងប្រព័ន្ធទិន្នន័យស្ថិតិប្រៃសណីយ៍មួយច្បាស់លាស់ ប្រកបដោយគុណភាព។
- ធ្វើការសិក្សា និងវិភាគលើសន្ទស្សន៍វាស់វែងកម្រិតនៃសមិទ្ធកម្ម ស្របតាមគោលការណ៍និយាម និងទម្រង់របស់សហភាពប្រៃសណីយ៍សកល ដើម្បីបង្កើតបានជាមូលដ្ឋាន សម្រាប់ជំរុញ និងកែសម្រួលការងារ សំដៅធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ ដែលមានកម្រិតប្រហាក់ប្រហែលនឹងបណ្ដាប្រទេសក្នុងតំបន់ ក្នុងការអភិវឌ្ឍប្រៃសណីយ៍។

## ៥.៣- លើកកម្ពស់សុវត្ថិភាពការងារ និងចីរភាពបរិស្ថាន ក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍

ក្នុងប្រតិបត្តិការនៃវិស័យប្រៃសណីយ៍ កម្លាំងពលកម្ម សម្ភារៈ ឧបករណ៍ជំនួយផ្សេងៗ និងមធ្យោបាយដឹកជញ្ជូន ត្រូវបានប្រើប្រាស់ជាចាំបាច់លើផ្នែកជាច្រើនដែលពាក់ព័ន្ធ។ ដើម្បីធានាបាននូវសុវត្ថិភាពនៅកន្លែងធ្វើការ និងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងវិស័យប្រៃសណីយ៍ដែលមានលក្ខណៈភាតរបរិស្ថាន ចាំបាច់ត្រូវជំរុញការយកចិត្តទុកដាក់លើការងារពាក់ព័ន្ធមួយចំនួន ដូចខាងក្រោម៖

- លើកទឹកចិត្តដល់ប្រតិបត្តិករ ក្នុងការរៀបចំបទដ្ឋានការងារផ្ទៃក្នុងអំពីសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ សម្រាប់និយោជិត ជាពិសេសនិយោជិតជាស្ត្រី ក្នុងខ្សែច្រវាក់ផលិតកម្ម ព្រមទាំងសិក្សា និងរៀបចំលក្ខខណ្ឌ និងបរិយាកាសការងារ ដែលជួយឱ្យនិយោជិតធ្វើការប្រកបដោយប្រសិទ្ធផលខ្ពស់។
- ជំរុញឱ្យប្រតិបត្តិករគិតគូរដល់ការងារបៃតង នៅក្នុងការវិនិយោគរបស់ខ្លួន ក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍ ក្នុងនោះប្រើប្រាស់សម្ភារៈបរិក្ខារ មធ្យោបាយផលិតកម្ម និងមធ្យោបាយដឹកជញ្ជូន ដែលអាចរក្សាការបំភាយកាបូនឱ្យនៅកម្រិតទាប កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន ជាអតិបរមា។ ជាមួយគ្នានេះដែរ ត្រូវជំរុញការចូលរួមការគ្រប់គ្រងកាកសំណល់ប្លាស្ទិកដោយអនុវត្តគោលការណ៍ 4R គឺ បដិសេធមិនប្រើប្រាស់ (Refuse) កាត់បន្ថយ (Reduce) ប្រើប្រាស់ឡើងវិញ (Reuse) និងកែច្នៃឡើងវិញ (Recycle)។

## ៥.៤- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញកស្តុភារកម្មប្រៃសណីយ៍ និង ជំរុញការធ្វើបរិវត្តកម្មឌីជីថលលើប្រព័ន្ធអេកូឡូស៊ីប្រៃសណីយ៍ សេវាកម្ម និងបណ្តាញប្រៃសណីយ៍

ការគាំទ្រលើការផ្តល់សេវាប្រៃសណីយ៍ក្នុងប្រព័ន្ធមួយដែលមានភាពប្រទាក់ក្រឡាគ្នា តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញកស្តុភារកម្មប្រៃសណីយ៍ នៅមានការខ្វះខាត និងមានកម្រិត។ ការរៀបចំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដែលតភ្ជាប់និងបំពេញឱ្យគ្នាទៅវិញទៅមក មានភាពចាំបាច់សម្រាប់ពង្រឹង និងពង្រីកការផ្តល់សេវាប្រៃសណីយ៍ ប្រកបដោយប្រសិទ្ធភាព និងបរិយាបន្ន ក៏ដូចជាគាំទ្រដល់ការធ្វើពិពិធកម្មសេវាក្នុងទីផ្សារ ការផ្តល់សេវាសាធារណៈរដ្ឋាភិបាលឌីជីថល និងការផ្តល់សេវាដឹកជញ្ជូនគោលដៅចុងក្រោយ (Last-Mile Delivery) នៅតាមតំបន់ប្រជុំជនរហូតដល់ជនបទ។ម្យ៉ាងវិញទៀត ការជំរុញការធ្វើបរិវត្តកម្មឌីជីថល (Digital Transformation) លើការផ្តល់សេវា និងក្នុងបណ្តាញប្រៃសណីយ៍ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (ICT) ប្រកបដោយនវានុវត្តន៍ នឹងបង្កលក្ខណៈដល់ការបង្កើនប្រសិទ្ធភាព គុណភាពសេវា ផ្តល់ទំនុកចិត្ត ធានានិរន្តរភាពនិងភាពធន់ ឆ្លើយតបទៅនឹងការវិវត្តនៃសង្គម និងសេដ្ឋកិច្ចឌីជីថល ជាពិសេស ទៅនឹងការផ្លាស់ប្តូរនៃបែបផែនពីការថយចុះនៃបញ្ញើប្រៃសណីយ៍ជាសំបុត្រ មកជាការកើនឡើងនូវបញ្ញើប្រៃសណីយ៍កញ្ចប់ជំនួសវិញ ស្របតាមការរីកដុះដាលនៃពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

ការងារអាទិភាពក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញកស្តុភារកម្មប្រៃសណីយ៍ និងក្នុងការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងបណ្តាញ និងសេវាកម្មប្រៃសណីយ៍ មានជាអាទិ៍៖

- ជំរុញ និងសម្របសម្រួលការពង្រីកមធ្យោបាយដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ និងបណ្តាញប្រៃសណីយ៍ តាមគ្រប់រូបភាព និងការបង្កើតឃ្លាំងកស្តុភារកម្មផ្លាស់ប្តូរបញ្ញើប្រៃសណីយ៍ ព្រមទាំងជំរុញឱ្យមានគោលការណ៍សហការផ្តល់សេវាបញ្ញើប្រៃសណីយ៍អន្តរប្រតិបត្តិករ ដើម្បីបំពេញឱ្យគ្នាទៅវិញទៅមករវាងប្រតិបត្តិករ នៅតាមភូមិសាស្ត្រ ដែលមានតម្រូវការចែកបញ្ញើទៅដល់គោលដៅចុងក្រោយ។
- រៀបចំប្រអប់សំបុត្រតាមលំនៅឋាន និងទីសាធារណៈ ប្រព័ន្ធលេខកូដប្រៃសណីយ៍ បញ្ជរនិងទូបញ្ញើឌីជីថល (Digital Lockers) ដោយកំណត់តំបន់ប្រជុំជនជាជម្រើសអាទិភាព និងបង្កើនប្រសិទ្ធភាពសេវាចែកបញ្ញើប្រៃសណីយ៍ក្នុងស្រុកដល់លំនៅឋាន។
- ពង្រីកសាខា ឬ ភ្នាក់ងារតំណាងផ្តល់សេវាប្រៃសណីយ៍រហូតដល់ថ្នាក់ឃុំ សំដៅបង្កើនបណ្តាញប្រៃសណីយ៍ឱ្យមានវិសាលភាពធំទូលាយ ខិតទៅដល់ប្រជាជននៅមូលដ្ឋាន។
- បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យប្រៃសណីយ៍ជាតិ (National Postal Information System) ដើម្បីគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យសេវាប្រៃសណីយ៍ ប្រកបដោយប្រសិទ្ធភាព សម្រាប់សេវាចែកបញ្ញើប្រៃសណីយ៍ក្នុងប្រទេស និងអាចតភ្ជាប់ទៅនឹងថ្នាល (Application

Program Interface – API) ដែលពាក់ព័ន្ធនឹងប្រតិបត្តិការប្រៃសណីយ៍ឯកជន ស្ថាប័នអន្តរជាតិក្នុងតំបន់ និងពិភពលោក និងប្រតិបត្តិការលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។

- អភិវឌ្ឍប្រព័ន្ធអាសយដ្ឋានប្រៃសណីយ៍ឌីជីថលជាតិ (National Digital Postal Addressing System) លេខកូដប្រៃសណីយ៍ឌីជីថលជាតិ (National Digital Postal Code) និងលេខកូដផែនទីឌីជីថលជាតិ (National Digital Map Code) និងចូលរួមអភិវឌ្ឍប្រព័ន្ធផ្តល់ព័ត៌មាន និងផែនទីភូមិសាស្ត្រឌីជីថលជំនួយដល់ការដឹកជញ្ជូន (Navigation Notification System) ដើម្បីធានាបាននូវប្រសិទ្ធភាព ភាពទាន់ពេលវេលា សុវត្ថិភាពនៃការដឹកជញ្ជូន និងផ្តល់ព័ត៌មានសេវាប្រៃសណីយ៍ដោយស្វ័យប្រវត្តិ អំពីការចែកបញ្ញើប្រៃសណីយ៍ជូនអតិថិជនទៅដល់គោលដៅ។
- រៀបចំប្រព័ន្ធអេកូឡូហ្ស៊ីប្រៃសណីយ៍ឌីជីថល តាមរយៈការបង្កើត និងប្រើប្រាស់ថ្នាលប្រៃសណីយ៍ឌីជីថល ដើម្បីគាំទ្រដល់ការផ្តល់សេវាប្រៃសណីយ៍ជូនអ្នកប្រើប្រាស់សេវា និងការដឹកជញ្ជូនគោលដៅចុងក្រោយ សំដៅគាំទ្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងជំរុញការធ្វើពិពិធកម្មសេវាប្រៃសណីយ៍, និងដើម្បីគាំទ្រ និងជំរុញការសហការលើការផ្តល់សេវាឌីជីថលផ្សេងៗ ក៏ដូចជាការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល (Digital Start-up) ប្រកបដោយនវានុវត្តន៍។
- រៀបចំយន្តការគាំទ្រ សហការ និងជួយសម្របសម្រួល ដើម្បីជំរុញការចូលរួមវិនិយោគឯកជនលើការអភិវឌ្ឍ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធកស្តុភារកម្មប្រៃសណីយ៍ តភ្ជាប់ពីតំបន់មួយទៅតំបន់មួយ សម្រាប់ពង្រីកបណ្តាញផ្តល់សេវាប្រៃសណីយ៍ ក្នុងទម្រង់ផ្សេងៗនៃការវិនិយោគរួមទាំងភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP)។ ក្រៅពីនេះ ជួយសម្របសម្រួលជំរុញការវិនិយោគ លើសម្ភារៈបរិក្ខារទ្រទ្រង់ឧស្សាហកម្មប្រៃសណីយ៍ ដូចជាគ្រឿងម៉ាស៊ីន ទូប្រអប់សំបុត្រស្វ័យប្រវត្តិ និងទូប្រអប់អាសយដ្ឋាន ជាដើម។

## ៥.៥-គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មផ្តល់សេវា ក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន

ក្នុងស្ថានភាពបច្ចុប្បន្ន ការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន នៅពុំទាន់ត្រូវបានគ្រប់គ្រងបានល្អប្រសើរ។ ការកំណត់បានច្បាស់លាស់នូវវិសាលភាពនៃការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន គឺជាផ្នែកមួយនៃការលើកកម្ពស់ការគ្រប់គ្រង ដើម្បីធានាការចូលរួមទ្រទ្រង់ការផ្តល់សេវាប្រៃសណីយ៍បានទូលំទូលាយ និងបង្កើនចំណូលចូលថវិកាជាតិ។ ប្រការនេះតម្រូវជាចាំបាច់ឱ្យកសាងក្របខណ្ឌគតិយុត្តគ្រប់ជ្រុងជ្រោយ ដែលកំណត់វិសាលភាពរួមជាមួយនឹងការបង្កើតយន្តការការងារសម្រាប់ការគ្រប់គ្រង និងគាំទ្រការធ្វើអាជីវកម្មផ្តល់សេវារបស់វិស័យឯកជន ក្រោមលក្ខខណ្ឌនៃការប្រកួតប្រជែងដោយសុចរិត។ លើសពីនេះ ត្រូវជំរុញការអនុវត្តការងារអាទិភាព ដូចខាងក្រោម៖

- ត្រួតពិនិត្យតាមដានវិសាលភាព និងស្ថានភាពបច្ចុប្បន្ននៃការធ្វើអាជីវកម្មបម្រើសេវា ក្នុងវិស័យប្រៃសណីយ៍ក្រៅផ្លូវការ ដើម្បីរៀបចំយន្តការជំរុញឱ្យប្រតិបត្តិករស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មក្នុងប្រព័ន្ធផ្លូវការ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្នុងយន្តការជំរុញនេះ ត្រូវ

យកចិត្តទុកដាក់កំណត់យកការរៀបចំកែសម្រួលនីតិវិធី និងការកាត់បន្ថយចំណាយទាំងពេលវេលា និងថវិកាក្នុងការស្នើសុំអាជ្ញាបណ្ណ ជាកិច្ចការអាទិភាពមួយ។

- លើកទឹកចិត្តប្រតិបត្តិករឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់សេវា ក្នុងវិស័យប្រៃសណីយ៍ ប្រកបដោយគុណភាព និងលើកទឹកចិត្តសហគ្រិនជាស្ត្រី ដើម្បីពង្រីកសហគ្រិនភាពរបស់ស្ត្រីក្នុងវិស័យប្រៃសណីយ៍។ ទន្ទឹមនឹងនេះ សម្រួលដល់ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត តាមរយៈយន្តការសម្រួលនីតិវិធីផ្តល់សេវាសាធារណៈរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដែលរួមមានប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃការផ្តល់សេវាសាធារណៈឌីជីថល។
- ផ្សព្វផ្សាយអំពីកាតព្វកិច្ច សិទ្ធិ ការទទួលខុសត្រូវ និងវិសាលភាពនៃការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍ ដែលមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដល់ប្រតិបត្តិករឱ្យបានទូលំទូលាយ និងជាប្រចាំ តាមរយៈការរៀបចំសិក្ខាសាលា និងវេទិកាផ្សេងៗ សំដៅផ្តល់ព័ត៌មានដល់ប្រតិបត្តិករ និងទទួលព័ត៌មានត្រឡប់ពីប្រតិបត្តិករ។
- សហការ និងសម្របសម្រួលប្រតិបត្តិករនៅក្នុងប្រទេស ឱ្យប្រើប្រាស់មជ្ឈមណ្ឌលផ្ទុក និងចែកបញ្ញើប្រៃសណីយ៍ និងប្រព័ន្ធទិន្នន័យចែកបញ្ញើប្រៃសណីយ៍ ប្រកបដោយតម្លាភាព។
- លើកទឹកចិត្តឱ្យប្រតិបត្តិករក្នុងវិស័យដឹកជញ្ជូនចុះកិច្ចសន្យាផ្តល់សេវាប្រៃសណីយ៍ ឬចុះកិច្ចសន្យាទទួលសិទ្ធិប្រកបអាជីវកម្ម (Franchise) ជាមួយសហគ្រាសប្រៃសណីយ៍កម្ពុជា ដើម្បីផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍។
- លើកទឹកចិត្តការចូលរួមវិនិយោគលើវិស័យប្រៃសណីយ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីជំរុញការប្រកួតប្រជែង។
- ជំរុញកិច្ចសហការរវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងការកំណត់ក្របខណ្ឌ វិធាន និងនីតិវិធីនៃការគ្រប់គ្រងលើការផ្តល់សេវាកម្មទទួល និងដឹកជញ្ជូនបញ្ញើរបស់ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងរថយន្តតាក់ស៊ីឯកជន ដោយក្នុងនោះអនុញ្ញាតឱ្យមានការផ្តល់សេវានេះក្នុងរយៈពេលខ្លី និងមធ្យមចំពោះមុខ ក្នុងលក្ខខណ្ឌដែលមានការគ្រប់គ្រងល្អប្រសើរ និងច្បាស់លាស់ សំដៅដោះស្រាយបញ្ហាប្រឈមនឹងហានិភ័យនៃការយឺតយ៉ាវ, បាត់បង់ និងខូចខាតបញ្ញើ ជាពិសេសសុវត្ថិភាព និងសន្តិសុខសាធារណៈ ហើយជាបណ្តើរៗ សម្រាប់រយៈពេលវែងខាងមុខ រៀបចំអភិវឌ្ឍប្រព័ន្ធផ្តល់សេវាបញ្ញើប្រៃសណីយ៍ស្របតាមស្តង់ដាឧត្តមានុវត្តន៍អន្តរជាតិ និងតម្រង់ទិសឱ្យអ្នកផ្តល់សេវាកម្មបញ្ញើទាំងអស់ចូលរួមផ្តល់សេវាផ្លូវការក្នុងប្រព័ន្ធមួយនេះ តាមរយៈការកែសម្រួលលិខិតបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង។

### ៥.៦- ជំរុញការបង្កើនសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជា ក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម

ប្រៃសណីយ៍កម្ពុជាបានបន្តអត្ថិភាពរបស់ខ្លួន ក្នុងឋានៈជាប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍ ស្ថិតក្រោមលក្ខន្តិកៈជាសហគ្រាសសាធារណៈ ដែលមានស្វ័យភាពលើការងាររដ្ឋបាលអាជីវកម្ម និងហិរញ្ញវត្ថុក្នុងការបំពេញបេសកកម្មផ្តល់សេវាប្រៃសណីយ៍ ដើម្បីចូលរួមចំណែកការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ ក្នុងទិសដៅលើកកម្ពស់ការផ្តល់សេវាប្រៃសណីយ៍ ដើម្បីបម្រើប្រជាជនឱ្យបានទូលំទូលាយ និងចូលរួមធានាប្រសិទ្ធភាពនៃសេដ្ឋកិច្ច ការពង្រឹងតួនាទីរបស់ប្រៃសណីយ៍កម្ពុជា ក្នុងបរិបទនៃការប្រកួតប្រជែងស្មើភាពជាមួយវិស័យឯកជនមានភាពចាំបាច់ ដែលតម្រូវឱ្យប្រៃសណីយ៍កម្ពុជាត្រូវបន្តបង្កើនសមត្ថភាពក្នុងការធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ការបង្កើនសមត្ថភាពនេះត្រូវគិតគូរទៅដល់ការកែទម្រង់ការងារ ការរៀបចំយុទ្ធសាស្ត្រធ្វើអាជីវកម្ម ក៏ដូចជាការអភិវឌ្ឍបច្ចេកវិទ្យា និងការពង្រីកបណ្តាញ ដើម្បីផ្តល់សេវាដល់ភូមិសាស្ត្រឃុំ-សង្កាត់។ ក្នុងន័យនេះ ត្រូវជំរុញប្រៃសណីយ៍កម្ពុជាឱ្យយកចិត្តទុកដាក់លើការងារ ជាអាទិ៍៖

- កែទម្រង់ការងារ និងរៀបចំយុទ្ធសាស្ត្រធ្វើអាជីវកម្មផ្តល់សេវា ដោយរួមបញ្ចូលទាំងការចាប់យកការដឹកជញ្ជូនសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងបរិបទនៃសេដ្ឋកិច្ចឌីជីថលសំដៅបង្កើនប្រភពចំណូល។
- អភិវឌ្ឍបន្ថែមនូវបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងអាជីវកម្ម និងការផ្សារភ្ជាប់ជាមួយប្រព័ន្ធប្រតិវេទន៍គយ (Customs Declaration System) ប្រព័ន្ធប្រៃសណីយ៍អន្តរជាតិ (International Postal System – IPS) និងការនាំចេញបញ្ញើប្រៃសណីយ៍ទៅក្រៅប្រទេស, ព្រមទាំងអភិវឌ្ឍបច្ចេកវិទ្យាក្នុងប្រតិបត្តិការទទួល និងចែកបញ្ញើប្រៃសណីយ៍, ធ្វើទំនើបកម្មមជ្ឈមណ្ឌលផ្លាស់ប្តូរបញ្ញើប្រៃសណីយ៍ (Office of Exchange), និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការដឹកជញ្ជូនសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- គ្រប់គ្រងការដឹកបញ្ញើប្រៃសណីយ៍ ពីមជ្ឈមណ្ឌលបែងចែកបញ្ញើប្រៃសណីយ៍ស្នាក់ការកណ្តាលភ្នំពេញទៅគ្រប់បណ្តាសាខាប្រៃសណីយ៍ខេត្ត និងការដឹកបញ្ញើប្រៃសណីយ៍រវាងសាខាប្រៃសណីយ៍ខេត្ត ដោយអភិវឌ្ឍបន្ថែមនូវមធ្យោបាយនិងបច្ចេកទេសសម្រាប់គ្រប់គ្រងបញ្ញើប្រៃសណីយ៍ និងផ្លាស់ប្តូរទិន្នន័យដឹកជញ្ជូនជាមួយដៃគូ។
- ធ្វើទំនើបកម្មសេវាប្រៃសណីយ៍រូបវន្តដែលមានស្រាប់ និងចូលរួមក្នុងការផ្តល់សេវាពហុមុខដោយរួមទាំងការចូលរួមផ្តល់សេវារដ្ឋាភិបាលឌីជីថល។
- កសាងសមត្ថភាព និងបណ្តុះបណ្តាលតម្រង់ទិសដៅការងាររបស់និយោជិតគ្រប់ជាន់ថ្នាក់ផ្លាស់ប្តូរផ្នត់គំនិតបែបមន្ត្រី ទៅជានិយោជិតបម្រើការងារសហគ្រាសបែបប្រកួតប្រជែង និងបង្កើនសមត្ថភាពដល់និយោជិតប្រើប្រាស់ឧបករណ៍តាមបច្ចេកវិទ្យា ICT។
- ពង្រីកសាខាតំណាង ឬ ភ្នាក់ងាររហូតដល់ឃុំ-សង្កាត់ តាមលំដាប់ភូមិសាស្ត្រ និងតាមដំណាក់កាល ដើម្បីទ្រទ្រង់ដល់សេវាប្រៃសណីយ៍។

## ៥.៧-បង្កើតកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល និងចូលរួមគាំទ្រផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល

ការបំពេញកាតព្វកិច្ចសេវាប្រៃសណីយ៍សកល (Universal Postal Service Obligation) គឺជាការធានាផ្តល់សេវាប្រៃសណីយ៍សកល (UPS) ឱ្យបានដល់គ្រប់ទីកន្លែង ងាយស្រួលប្រើ មានតម្លៃសមរម្យ ឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាជន និងចូលរួមផ្តល់សេវាសាធារណៈ ប្រកបដោយនិរន្តរភាព និងបរិយាបន្ន។ កាតព្វកិច្ចសេវាប្រៃសណីយ៍សកល រួមជាមួយនឹងវិសាលភាពនៃការផ្តល់សេវា សិទ្ធិ សមត្ថកិច្ចគ្រប់គ្រង ករណីយកិច្ច និងការទទួលខុសត្រូវរបស់ប្រតិបត្តិករផ្តល់សេវា និងយន្តការគាំទ្រ នឹងត្រូវកំណត់ដោយបទប្បញ្ញត្តិ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវកំណត់ជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងការបំពេញកាតព្វកិច្ចសេវាប្រៃសណីយ៍សកល ហើយប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍ជាប្រតិបត្តិករសំខាន់មួយក្នុងការបំពេញកាតព្វកិច្ចនេះ។ សេវាប្រៃសណីយ៍សកល នឹងផ្តល់ជូនសាធារណជនតាមយន្តការដាច់ដោយឡែក ក្រោមបទប្បញ្ញត្តិ ដែលកំណត់នូវគុណភាពជាមូលដ្ឋាន តម្លៃសមរម្យ ព្រមទាំងសិទ្ធិ និងករណីយកិច្ចបន្ថែមរបស់ប្រតិបត្តិករក្នុងការផ្តល់សេវា។ ប្រតិបត្តិករប្រៃសណីយ៍ឯកជនក៏ត្រូវបានលើកទឹកចិត្តឱ្យចូលរួមអនុវត្តកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល ស្របតាមការកំណត់នៃបទប្បញ្ញត្តិ។

សេវាប្រៃសណីយ៍សកល ដែលផ្តល់ដោយប្រតិបត្តិករជាតិត្រូវតែស្ថិតស្ថេរ និងធានាបាននូវនិរន្តរភាព។ ក្នុងករណីនេះ ដើម្បីអាចឱ្យសេវាប្រៃសណីយ៍សកលដំណើរការបានពេញលេញនិងរលូន ប្រតិបត្តិករជាតិគួរទទួលបាននូវការគាំទ្រចេញពីប្រភពផ្សេងៗ ជាអាទិ៍ ដៃគូអភិវឌ្ឍន៍ ការសហការជាមួយប្រតិបត្តិករឯកជន កិច្ចសហប្រតិបត្តិការផ្សេងទៀត ដើម្បីបង្កើនសមត្ថភាពរបស់ប្រតិបត្តិករជាតិ លើដំណើរការអភិវឌ្ឍអាជីវកម្មស្របតាមយុទ្ធសាស្ត្រអាជីវកម្ម ដោយរួមទាំងការធ្វើទំនើបកម្ម ការពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញប្រៃសណីយ៍ដល់ឃុំ-សង្កាត់។ ការបង្កើនសមត្ថភាពដើម្បីសម្រេចបានប្រាក់ចំណេញ ប្រកបដោយនិរន្តរភាពក្នុងធុរកិច្ចរបស់ប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍ គឺជាប្រភពគាំទ្រដ៏សំខាន់ដល់ការបំពេញកាតព្វកិច្ចសេវាប្រៃសណីយ៍សកល។ ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចពិចារណាចាត់វិធានការជួយគាំទ្រដល់ការពង្រឹង និងការបង្កើនសមត្ថភាពរបស់ប្រតិបត្តិករជាតិ ក្នុងការអនុវត្តកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកលនេះ។

ម្យ៉ាងទៀត ការជំរុញឱ្យប្រៃសណីយ៍កម្ពុជាចូលរួមក្នុងការផ្តល់សេវាសាធារណៈ តាមរយៈការដឹកជញ្ជូន និងចែកបញ្ញើប្រៃសណីយ៍ ដើម្បីគាំទ្រសេវាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល គឺជាការចូលរួមដ៏សំខាន់មួយទៀតក្នុងការផ្តល់សេវាប្រៃសណីយ៍ ដើម្បីបម្រើផលប្រយោជន៍ជូនប្រជាជន។ ការណ៍នេះ តម្រូវជាចាំបាច់ ឱ្យប្រតិបត្តិករជាតិធ្វើការកែលម្អរបៀបរបបការងារ លើកកម្ពស់គុណភាពសេវាផ្នែកជួរមុខ បង្កើនសមត្ថភាពផ្នែកទ្រទ្រង់ និងកសាងសមត្ថភាពរបស់និយោជិត។ ក្នុងបរិបទនេះ ការងារសំខាន់ៗដែលត្រូវសម្របសម្រួល ដើម្បីជំរុញការអនុវត្ត មានជាអាទិ៍៖ រៀបចំកិច្ចព្រមព្រៀងក្នុងការផ្តល់សេវាសាធារណៈដោយមានការផ្សព្វផ្សាយ តាមប្រព័ន្ធអេឡិចត្រូនិក និងការរៀបចំសិក្ខាសាលា, កំណត់ការិយាល័យប្រៃសណីយ៍អាទិភាព ដែលត្រូវទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈ, ផ្តល់ព័ត៌មាន និងសេវា តាមប្រព័ន្ធអេឡិច-

គ្រូនិក, បណ្តុះបណ្តាលមន្ត្រី ដើម្បីអនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាព ដើម្បីកែលម្អនីតិវិធី និងយន្តការក្នុងការផ្តល់សេវា, រៀបចំ និងអនុវត្តយន្តការទទួលព័ត៌មានត្រឡប់ពីការប្រើប្រាស់សេវា, ដោះស្រាយបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់សេវា។

### ៥.៨- ជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យប្រៃសណីយ៍

ការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យប្រៃសណីយ៍ គឺជាការជួយគាំទ្រដល់ការអភិវឌ្ឍ ការធ្វើពិពិធកម្ម និងការផ្តល់សេវា ប្រកបដោយភាពច្នៃប្រឌិត ដើម្បីឆ្លើយតបទៅនឹងតម្រូវការប្រើប្រាស់លើសេវាគ្រប់ប្រភេទ។ ដូច្នេះ ចាំបាច់ត្រូវមានផែនការការងារជំរុញការអប់រំ និងបណ្តុះបណ្តាលដូចខាងក្រោម៖

- រៀបចំ និងអនុវត្តកម្មវិធីសិក្សារយៈពេលខ្លី មធ្យម និងវែង និងទស្សនកិច្ចសិក្សា ដើម្បីបង្កើនចំណេះដឹង និងបទពិសោធន៍លើការអភិវឌ្ឍវិស័យប្រៃសណីយ៍ សម្រាប់ស្ថាប័ន និងអង្គភាពដែលពាក់ព័ន្ធ និងដើម្បីអភិវឌ្ឍចំណេះដឹង និងជំនាញ ដល់អ្នកទទួលបន្ទុកការងារអភិវឌ្ឍវិស័យប្រៃសណីយ៍។
- ផ្តល់ការអប់រំបណ្តុះបណ្តាលលើជំនាញផ្នែកគ្រប់គ្រង ការរៀបចំផែនការ និងការសម្របសម្រួល និងចំណេះដឹងផ្នែកបច្ចេកវិទ្យា តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានទទួលបន្ទុកការអប់រំបណ្តុះបណ្តាល ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អង្គការក្នុងតំបន់ និងអង្គការអន្តរជាតិនានា ជាពិសេស ជាមួយសហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (APPU) និងសហភាពប្រៃសណីយ៍សកល (UPU) ដើម្បីចូលរួមវគ្គសិក្សាតាមប្រព័ន្ធអនឡាញ និងវគ្គសិក្សានានារបស់វិទ្យាស្ថានប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (Asian-Pacific Postal College) ដែលជាប្រភពផ្តល់ចំណេះដឹង បទពិសោធ និងយុទ្ធសាស្ត្រឆ្ពោះទៅមុខដ៏សំខាន់សម្រាប់វិស័យប្រៃសណីយ៍។
- ជំរុញការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជន លើចំណេះដឹងនិងជំនាញនៃវិស័យប្រៃសណីយ៍ និងឌីជីថល តាមរយៈការរៀបចំវគ្គសិក្សា វេទិកា សិក្ខាសាលា កម្មវិធីផ្សព្វផ្សាយ ផ្លាស់ប្តូរ និងចែករំលែកព័ត៌មាន ព្រមទាំងបង្កភាពងាយស្រួលដល់ការបន្សាំ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងវិស័យប្រៃសណីយ៍។

បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានបានធ្វើឱ្យមានការផ្លាស់ប្តូរបែបបទនៃទំនាក់ទំនងសង្គម និងធ្វើឱ្យពាណិជ្ជកម្មតាមរយៈលិខិតជាលក្ខណៈប្រពៃណី មានការធ្លាក់ចុះយ៉ាងខ្លាំង។ ដើម្បីឆ្លើយតបទៅនឹងបញ្ហានេះ ទាមទារឱ្យបណ្តាប្រតិបត្តិករក្នុងវិស័យប្រៃសណីយ៍ ត្រូវធ្វើពិពិធកម្ម និងផ្តល់ជូនដល់អ្នកប្រើប្រាស់នូវប្រភេទសេវាប្រៃសណីយ៍បែបថ្មីក្នុងយុគសម័យនៃសេដ្ឋកិច្ចឌីជីថល។ ក្នុងបរិការណ៍នេះ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវដាក់ចេញនូវយន្តការជំរុញនវានុវត្តន៍នៃសេវាប្រៃសណីយ៍ ដែលរួមមានការស្រាវជ្រាវ និងអភិវឌ្ឍន៍ ព្រមទាំងសម្របសម្រួល ប្រកបដោយនិរន្តរភាព ឱ្យមានវេទិកាជួបគ្នារវាងប្រតិបត្តិករផ្តល់សេវា អ្នកប្រើប្រាស់សេវា និងអ្នកជំនាញបច្ចេកទេស ដើម្បីអភិវឌ្ឍសេវាប្រៃសណីយ៍ឌីជីថល (Digital

Postal Service) សម្រាប់គាំទ្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការដឹកជញ្ជូនគោលដៅចុងក្រោយ និងវឌ្ឍនភាពសង្គម។

## ៦- ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ផែនការសកម្មភាពសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់អនុវត្តជាចាំបាច់ រួមមាន៖

### ៦.១- ការបង្កើតយន្តការសហការ សម្របសម្រួល និងអនុវត្ត

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ ទាមទារឱ្យមានការបង្កើតយន្តការនៃកិច្ចសហការ ការសម្របសម្រួល និងការអនុវត្តដូចខាងក្រោម៖

- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដែលទទួលបន្ទុកជាសេនាធិការផ្ទាល់ របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងវិស័យប្រៃសណីយ៍នៅកម្ពុជា ត្រូវរៀបចំការអនុវត្តគោលនយោបាយនេះឱ្យសម្រេចបានតាមគោលដៅ និងយុទ្ធសាស្ត្រនៃគោលនយោបាយ ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ វិស័យឯកជន អង្គការជាតិ និងអន្តរជាតិ ព្រមទាំងរៀបចំ និងជំរុញការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដែលចង្អុលដោយគោលនយោបាយ។
- អគ្គនាយកដ្ឋានប្រៃសណីយ៍ មានសមត្ថកិច្ចជាសេនាធិការរបស់ក្រសួងទទួលខុសត្រូវក្នុងការសម្របសម្រួលការអនុវត្ត និងការតាមដានត្រួតពិនិត្យ។ អគ្គនាយកដ្ឋានប្រៃសណីយ៍ត្រូវបានគាំទ្រដោយអង្គភាពបច្ចេកទេសពាក់ព័ន្ធនានា ដែលស្ថិតនៅក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រោមការជួយសម្របសម្រួលពីក្រុមការងារប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។
- ក្រៅពីការជួយសម្របសម្រួលខាងលើ ក្រុមការងារប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ នឹងបំពេញតួនាទីផ្តល់ប្រឹក្សាយោបល់លើការរៀបចំបង្កើត និងអនុវត្តគម្រោង ឬកម្មវិធីទាក់ទងនឹងការអភិវឌ្ឍវិស័យប្រៃសណីយ៍ក្រោមក្របខណ្ឌគោលនយោបាយនេះ។

### ៦.២- កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ

ការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងការផ្តល់សេវាប្រៃសណីយ៍សកល ត្រូវមានការចូលរួមសហការគាំទ្រពីគ្រប់តួអង្គពាក់ព័ន្ធ ដែលរួមមានក្រសួង-ស្ថាប័ន អង្គការជាតិ និងអន្តរជាតិ ក្នុងក្របខណ្ឌរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល ជាទ្វេភាគីនិងពហុភាគី ដើម្បីជំរុញការកសាង និងអភិវឌ្ឍគ្រប់សមាសធាតុ ប្រកបដោយប្រសិទ្ធភាពខ្ពស់ នៅគ្រប់ដំណាក់កាល។ ក្នុងន័យនេះ កិច្ចការសហការត្រូវផ្តោតការយកចិត្តទុកដាក់ ដូចខាងក្រោម៖

- ក្នុងក្របខណ្ឌជាតិ សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ជាអាទិ៍ ៖ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា រដ្ឋបាលរាជធានីភ្នំពេញ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ សមាគមដឹកជញ្ជូន សមាគមកស្តុភារកម្មកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលនានា។

- ក្នុងក្របខណ្ឌអន្តរជាតិ សហការជាមួយប្រទេសក្នុងក្របខណ្ឌតំបន់អាស៊ាន សហភាពប្រៃសណីយ៍សកល (UPU) សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក (APPU) អង្គការគយពិភពលោក (WCO) អង្គការពាណិជ្ជកម្មពិភពលោក (WTO) អង្គការដឹកជញ្ជូនតាមផ្លូវអាកាស (IATA) អង្គការអាកាសចរស៊ីវិលអន្តរជាតិ (ICAO) និងដៃគូអភិវឌ្ឍន៍នានា។
- តាមដាន និងអនុវត្តសេចក្តីសម្រេច និងយុទ្ធសាស្ត្រថ្មីៗរបស់សហភាពប្រៃសណីយ៍សកល និងបណ្តាអង្គការពាក់ព័ន្ធ។

### ៦.៣- ការពង្រឹងក្របខណ្ឌគតិយុត្ត

រាល់ការរៀបចំលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ ត្រូវពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៃក្រសួង-ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការនានា ដើម្បីធានាប្រសិទ្ធភាព ក្នុងការអនុវត្តគោលនយោបាយនេះស្របតាមចក្ខុវិស័យដែលបានកំណត់។ ច្បាប់ស្តីពីសេវាប្រៃសណីយ៍ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ មានភាពបន្ទាន់ដែលត្រូវរៀបចំនិងអនុម័ត ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងការគ្រប់គ្រងការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍របស់ប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន។

### ៦.៤- ការគាំទ្រហិរញ្ញវត្ថុ

ហិរញ្ញប្បទានសម្រាប់ការអនុវត្តសកម្មភាពគាំទ្រ ដើម្បីសម្រេចបានតាមគោលដៅរបស់គោលនយោបាយ មានប្រភពមកពីថវិកាជាតិ ហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងប្រភពស្របច្បាប់ផ្សេងទៀត។

### ៦.៥- ការបណ្តុះបណ្តាលធនធានមនុស្ស

ការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានប្រៃសណីយ៍ ត្រូវធ្វើការកែសម្រួលឡើងវិញជាចាំបាច់ ដើម្បីកំណត់តួនាទីភារកិច្ចឱ្យឆ្លើយតបទៅនឹងនិន្នាការផ្លាស់ប្តូរក្នុងតម្រូវការនៃការអភិវឌ្ឍវិស័យប្រៃសណីយ៍។ ព្រមជាមួយគ្នានេះ ត្រូវយកចិត្តទុកដាក់ធ្វើការជ្រើសរើសមន្ត្រី និងចាត់តាំងឱ្យបម្រើការងារដែលមានលក្ខណៈឆ្លើយតប ព្រមទាំងរៀបចំផែនការបណ្តុះបណ្តាលដូចខាងក្រោម៖

- ធ្វើការវាយតម្លៃអំពីតម្រូវការបណ្តុះបណ្តាល សម្រាប់មន្ត្រីនៅគ្រប់ជាន់ថ្នាក់ និងគ្រប់ផ្នែក។
- រៀបចំវគ្គបណ្តុះបណ្តាលទាំងនៅក្នុង និងក្រៅប្រទេសសម្រាប់មន្ត្រី ដោយផ្សារភ្ជាប់ជាមួយគោលគំនិតនៃការអភិវឌ្ឍវិស័យប្រៃសណីយ៍ក្នុងយុគសម័យសេដ្ឋកិច្ចឌីជីថល និងរៀបចំវេទិកាថ្នាក់ជាតិ ដើម្បីបង្កើនការយល់ដឹងនិងចំណេះដឹង ផ្លាស់ប្តូរគំនិតយោបល់ និងចែករំលែកបទពិសោធន៍ជាមួយនឹងការអញ្ជើញគ្រូឧទ្ទេស និងវាគ្មិនជំនាញចូលរួម។

- សហការជាមួយបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលលើផ្នែកបច្ចេកទេស និងអភិបាលកិច្ចពាក់ព័ន្ធនឹងវិស័យប្រៃសណីយ៍ រួមទាំងការងារគ្រប់គ្រងការរៀបចំផែនការ និងការសម្របសម្រួល។
- រៀបចំគម្រោង ដើម្បីស្នើសុំប្រើប្រាស់មូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវ និងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន ដើម្បីបង្កើតជំនាញប្រើប្រាស់ និងអភិវឌ្ឍបច្ចេកវិទ្យា ដោយផ្សារភ្ជាប់ជាមួយនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍។

### ៦.៦- ដំណើរការអនុវត្តគម្រោង

ផែនការសកម្មភាពលម្អិត នឹងត្រូវរៀបចំសម្រាប់អនុវត្តជាក់ស្តែងក្នុងរយៈពេលពីឆ្នាំ២០២២ ដល់ឆ្នាំ២០៣០ យោងតាមតារាងសកម្មភាពអាទិភាព ដែលមានបង្ហាញក្នុងឧបសម្ព័ន្ធ១ ដោយមានការផ្តល់យោបល់ពីក្រុមការងារប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយពាក់ព័ន្ធ ជាពិសេស ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ ដើម្បីធានាភាពជោគជ័យ ក្នុងដំណើរការអនុវត្តផែនការសកម្មភាព ដែលបានដាក់ចេញស្របតាមឯកសារគោលនយោបាយនេះ ឆន្ទៈនយោបាយនិងការចូលរួមរបស់តួអង្គពាក់ព័ន្ធគឺជាកត្តាកំណត់ដ៏សំខាន់។ ដូច្នេះការគ្រប់គ្រងហានិភ័យ ដែលទាក់ទងនឹងការសម្របសម្រួលស្ថាប័ន នឹងត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាការចូលរួមរបស់ភាគីពាក់ព័ន្ធ ជាមួយនឹងការអនុវត្តតួនាទី ប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការប្រើប្រាស់ធនធានចាំបាច់ ទាំងធនធានហិរញ្ញវត្ថុ ទាំងធនធានមនុស្ស។ ដើម្បីបញ្ចៀសហានិភ័យក្នុងពេលអនុវត្តគោលនយោបាយ គ្រប់តួអង្គពាក់ព័ន្ធ ត្រូវបានជំរុញឱ្យចូលរួមអភិវឌ្ឍវិស័យប្រៃសណីយ៍ ប្រកបដោយការទទួលខុសត្រូវ ដោយធ្វើការចាត់តាំងតំណាងដែលមានសមត្ថកិច្ចក្នុងការងារ ដើម្បីរួមសហការអនុវត្តយ៉ាងជិតស្និទ្ធនូវរាល់បណ្តាផែនការសកម្មភាពពាក់ព័ន្ធក្នុងយន្តការអន្តរស្ថាប័ន ក្រោមការសម្របសម្រួលរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានមន្ត្រីតំណាងរបស់អគ្គនាយកដ្ឋានប្រៃសណីយ៍ជាសេនាធិការ។ ឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍នឹងត្រូវពិនិត្យឡើងវិញ ដើម្បីពិនិត្យលទ្ធភាពនៃការធ្វើបច្ចុប្បន្នកម្ម និងអនុវត្តបន្ត។

## ៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

ដើម្បីអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព ប្រសិទ្ធផល និងធានាបាននូវវឌ្ឍនភាពជាបន្តចាំបាច់ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យ តាមដាន និងវាយតម្លៃ ដោយកំណត់សូចនាករច្បាស់លាស់ ដែលអាចវាស់វែងបាន។ ផ្អែកលើប្រព័ន្ធនេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំចេញជារបាយការណ៍ដូចខាងក្រោម៖

- របាយការណ៍វាយតម្លៃ នៃការប្រៀបធៀបលទ្ធផលសម្រេចបាន ទៅនឹងសូចនាករដែលបានកំណត់ក្នុងគោលដៅនៃគោលនយោបាយ ដោយត្រូវធ្វើពីរដងក្នុងរយៈពេលនៃគោលនយោបាយ គឺលើកទីមួយ រៀបចំរបាយការណ៍ពាក់កណ្ដាលអាណត្តិ ដើម្បីពិនិត្យវាយតម្លៃ និងលើកជាអនុសាសន៍សម្រាប់កែសម្រួលគោលនយោបាយក្នុងករណីចាំបាច់ និងលើកទីពីរ រៀបចំរបាយការណ៍នៅឆ្នាំបញ្ចប់,
- របាយការណ៍វឌ្ឍនភាពដែលត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានវិធានការចាំបាច់ ក្នុងការដោះស្រាយបញ្ហាប្រឈមចំពោះមុខ និងបន្តអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យ, និង
- របាយការណ៍វាយតម្លៃលើការអនុវត្តសកម្មភាពអាទិភាពនីមួយៗ ដែលបានកំណត់ក្នុងគោលនយោបាយ។

អគ្គនាយកដ្ឋានប្រៃសណីយ៍នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃ ដែលរួមមានវិធីសាស្ត្រស្រាវជ្រាវ ប្រមូល និងវិភាគទិន្នន័យ និងយន្តការរាយការណ៍ ដើម្បីមានមូលដ្ឋានឈានទៅរៀបចំបូកសរុប ទាំងរបាយការណ៍វាយតម្លៃ ទាំងរបាយការណ៍វឌ្ឍនភាព។

## ៨- សន្និដ្ឋាន

ឯកសារគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ គឺជាផែនទីបង្ហាញផ្លូវនាំឆ្ពោះទៅរកការសម្រេចបាននូវការលើកកម្ពស់ការផ្ដល់សេវាប្រៃសណីយ៍ ប្រកបដោយនិរន្តរភាព មានគុណភាព និងមានវិសាលភាពគ្របដណ្ដប់ទូលំទូលាយដល់តំបន់ជនបទ ក្នុងប្រព័ន្ធជាតិដែលមានភាពប្រទាក់ក្រឡាគ្នា ដើម្បីរួមចំណែកបម្រើ និងផ្ដល់ផលប្រយោជន៍ដល់ប្រជាជន ទាំងលើទិដ្ឋភាពសេដ្ឋកិច្ច ទាំងលើទិដ្ឋភាពសង្គម ព្រមទាំងធ្វើឱ្យវិស័យប្រៃសណីយ៍សម្រេចបាននូវសក្ដានុពលពេញលេញ ជាវិស័យចូលរួមចំណែកគាំទ្រពិពិធកម្មសេដ្ឋកិច្ចកម្ពុជា។ គោលនយោបាយនេះ រួមជាមួយនឹងច្បាប់ស្ដីពីសេវាប្រៃសណីយ៍ ដែលនឹងរៀបចំអនុម័ត តាមការចង្អុលបង្ហាញរបស់គោលនយោបាយ អាចផ្ដល់ក្របខណ្ឌជាមូលដ្ឋានសម្រាប់ជាដំណោះស្រាយលើបញ្ហាប្រឈមនានា ដែលរួមមាន ទាំងការងារសម្របសម្រួល ទាំងការបង្កើតបរិយាកាសសម្រាប់ការអភិវឌ្ឍវិស័យប្រៃសណីយ៍ក្នុងបរិបទនៃតម្រូវការ និងការផ្លាស់ប្ដូរដែលបាននិងកំពុងកើតមាន។

ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផលលើគោលនយោបាយ តម្រូវឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ចូលរួមសហការគាំទ្រឱ្យបានពេញទំហឹង សំដៅសម្រេចឱ្យបាននូវកិច្ចការសំខាន់ៗ ជាអាទិ៍ៈ ការដោះស្រាយបញ្ហាប្រឈម ការកៀរគរបានធនធានសម្រាប់វិនិយោគ ការធ្វើនិយ័តកម្ម ការលើកកម្ពស់ការគ្រប់គ្រងការធ្វើអាជីកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបំពេញតួនាទីឱ្យបានម៉ឺងម៉ាត់ក្នុងការគាំទ្រ និងសម្របសម្រួលដល់ការជំរុញការអនុវត្តនូវរាល់សកម្មភាពទៅតាមផែនការដែលបានកំណត់នៅក្នុងគោលនយោបាយ។

ដើម្បីសម្រេចបានលទ្ធផលជាក់ស្ដែង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អង្គភាពក្រោមចំណុះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ពិតជាមានកិច្ចការជា

ច្រើនដែលត្រូវអនុវត្ត។ ប៉ុន្តែ ជាមួយនឹងការរំពឹងទុកថាគ្រប់តួអង្គទាំងអស់មានឆន្ទៈនយោបាយ និងការប្ដេជ្ញាចិត្តខ្ពស់ គោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០ នឹងត្រូវបានអនុវត្តប្រកបដោយជោគជ័យ តាមរយៈការសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅរបស់គោលនយោបាយក្រោមការសម្របសម្រួលរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

## ឧបសម្ព័ន្ធ១ : តារាងសកម្មភាពអាទិភាពនៃគោលនយោបាយ

| ល.រ. | យុទ្ធសាស្ត្រ | | សកម្មភាព | ស្ថាប័ន/អង្គភាព ទទួលខុសត្រូវ | រយៈពេល |
|---|---|---|---|---|---|
| ១ | ពង្រឹងក្របខណ្ឌគតិយុត្ត ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យប្រៃសណីយ៍ | ១.១ | រៀបចំច្បាប់ស្ដីពីសេវាប្រៃសណីយ៍ និងលិខិតបទដ្ឋានគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ក្រុមការងារនីតិកម្ម | រយៈពេលខ្លី-មធ្យម |
| ២ | បង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍ និងការពារអ្នកប្រើប្រាស់ | ២.១ | ពិនិត្យតាមដានគុណភាពជាប់ជាប្រចាំនូវការផ្ដល់សេវាប្រៃសណីយ៍សកល និងការផ្ដល់សេវាប្រៃសណីយ៍ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ២.២ | បង្កើតប្រព័ន្ធឌីជីថល (ថ្នាល) ដើម្បីត្រួតពិនិត្យតាមដានការគ្រប់-គ្រងគុណភាពនៃការផ្ដល់សេវាប្រៃសណីយ៍និងវាយតម្លៃពីវឌ្ឍនភាពនៃការផ្ដល់សេវាជាក់ស្ដែងរបស់អ្នកផ្ដល់សេវាប្រៃសណីយ៍ ធៀបនឹងសូចនាករគុណភាពសេវា ដែលបានធ្វើស្វ័យប្រកាស និងផ្សព្វផ្សាយជាសាធារណៈនូវនិយាមនៃការផ្ដល់សេវារបស់អ្នកផ្ដល់សេវា | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលមធ្យម |
| | | ២.៣ | បង្កើតយន្តការដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកប្រើប្រាស់ដែលមិនបានពេញចិត្តនឹងដំណោះស្រាយរបស់អ្នកផ្ដល់សេវា | - គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់<br>- អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី |
| | | ២.៤ | ប្រមូលចងក្រងទិន្នន័យ និងកំណត់សូចនាកររាស់វែងសំខាន់ៗ និងធ្វើការសិក្សា និងវិភាគជាប្រចាំលើសន្ទស្សន៍វាស់វែងកម្រិតនៃសមិទ្ធកម្ម | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី |

| | | | | | |
|---|---|---|---|---|---|
| ៣ | លើកកម្ពស់សុវត្ថិភាពការងារនិងចីរភាពបរិស្ថានក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍ | ៣.១ | លើកទឹកចិត្តដល់ប្រតិបត្តិករ ក្នុងការរៀបចំបទដ្ឋានការងារផ្ទៃក្នុងអំពីសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការ ព្រមទាំងសិក្សា និងរៀបចំលក្ខខណ្ឌ និងបរិយាកាសការងារដែលជួយឱ្យនិយោជិតធ្វើការប្រកបដោយប្រសិទ្ធផលខ្ពស់ | - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (អគ្គនាយកដ្ឋានប្រៃសណីយ៍)<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន | រយៈពេលខ្លី-វែង |
| | | ៣.២ | ជំរុញឱ្យប្រតិបត្តិករគិតគូរដល់ការងារបៃតងនៅក្នុងការវិនិយោគរបស់ខ្លួនក្នុងប្រតិបត្តិការអាជីវកម្មប្រៃសណីយ៍ និងត្រូវជំរុញការចូលរួមការគ្រប់គ្រងកាកសំណល់ប្លាស្ទិក ដោយអនុវត្តគោលការណ៍ 4R | - ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (អគ្គនាយកដ្ឋានប្រៃសណីយ៍)<br>- ក្រសួងបរិស្ថាន<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន | រយៈពេលខ្លី-វែង |
| ៤ | អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តបណ្តាញភស្តុភារកម្មប្រៃសណីយ៍ និងជំរុញការធ្វើបរិវត្តកម្មឌីជីថលលើប្រព័ន្ធអេកូឡូហ្ស៊ីប្រៃសណីយ៍ សេវាកម្មនិងបណ្តាញប្រៃសណីយ៍ | ៤.១ | ជំរុញ និងសម្របសម្រួលការពង្រីកមធ្យោបាយដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ បណ្តាញប្រៃសណីយ៍តាមគ្រប់រូបភាព និងការបង្កើតឃ្លាំងភស្តុភារកម្មប្រៃសណីយ៍ផ្លាស់ប្តូរបញ្ញើប្រៃសណីយ៍ | - អគ្គនាយដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន | រយៈពេលខ្លី-មធ្យម |
| | | ៤.២ | រៀបចំប្រអប់សំបុត្រតាមលំនៅឋាន និងទីសាធារណៈ ប្រព័ន្ធលេខកូដប្រៃសណីយ៍ បញ្ជរ និងទូបញ្ញើឌីជីថល | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៤.៣ | បង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានវិស័យប្រៃសណីយ៍ជាតិ ប្រព័ន្ធអាសយដ្ឋានប្រៃសណីយ៍ឌីជីថលជាតិ លេខកូដប្រៃសណីយ៍ឌីជីថលជាតិ និងលេខកូដផែនទីឌីជីថលជាតិ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ (អគ្គនាយកដ្ឋានប្រៃសណីយ៍) | រយៈពេលមធ្យម-វែង |

| | | | | | |
|---|---|---|---|---|---|
| | | | | - ក្រសួងមហាផ្ទៃ<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | |
| | | ៤.៤ | បង្កើត និងប្រើប្រាស់ថ្នាលប្រៃសណីយ៍ឌីជីថល ដើម្បីគាំទ្រដល់ការផ្តល់សេវាប្រៃសណីយ៍ និងការដឹកជញ្ជូនគោលដៅចុងក្រោយសំដៅគាំទ្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនិងជំរុញការធ្វើពិពិធកម្មសេវាប្រៃសណីយ៍ និងការលើកទឹកចិត្តធុរកិច្ចថ្មីឌីជីថល ប្រកបដោយនវានុវត្តន៍ | - អគ្គនាយដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន | រយៈពេលមធ្យម-វែង |
| | | ៤.៥ | រៀបចំយន្តការជួយសម្របសម្រួល ដើម្បីជំរុញការចូលរួមវិនិយោគឯកជនលើការអភិវឌ្ឍ និងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធភស្តុភារ-កម្មប្រៃសណីយ៍ និងជំរុញការវិនិយោគលើសម្ភារៈបរិក្ខារទ្រទ្រង់ឧស្សាហកម្មប្រៃសណីយ៍ | - អគ្គនាយដ្ឋានប្រៃសណីយ៍<br>- វិស័យឯកជន | រយៈពេលខ្លី-វែង |
| ៥ | គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍របស់ផ្នែកឯកជន | ៥.១ | កសាងក្របខណ្ឌគតិយុត្តគ្រប់ជ្រុងជ្រោយ ដែលកំណត់វិសាលភាពរួមជាមួយនឹងការបង្កើតយន្តការការងារ សម្រាប់ការគ្រប់គ្រង និងគាំទ្រ ការធ្វើអាជីវកម្មផ្តល់សេវារបស់វិស័យឯកជន | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ក្រុមការងារនីតិកម្ម | រយៈពេលខ្លី |
| | | ៥.២ | - ត្រួតពិនិត្យតាមដានជាប្រចាំនូវវិសាលភាព និងស្ថានភាពបច្ចុប្បន្ននៃការធ្វើអាជីវកម្មបម្រើសេវាក្នុងវិស័យប្រៃសណីយ៍ក្រៅផ្លូវការ ដើម្បីរៀបចំយន្តការជំរុញឱ្យប្រតិបត្តិករស្នើសុំអាជ្ញាបណ្ណធ្វអាជីវ-កម្ម<br>- ត្រូវយកចិត្តទុកដាក់កំណត់យកការរៀបចំកែសម្រួលនីតិវិធី និងការកាត់បន្ថយចំណាយទាំងពេលវេលា និងថវិកា ក្នុងការស្នើសុំអាជ្ញាបណ្ណ ជាកិច្ចការអាទិភាព | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |

| | | | | | |
|---|---|---|---|---|---|
| | | ៥.៣ | - លើកទឹកចិត្តប្រតិបត្តិករឱ្យប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងការផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍<br>- សម្រួលដល់ការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតតាមរយៈយន្តការសម្រួលនីតិវិធីផ្តល់សេវាសាធារណៈ ដែលរួមមានប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការផ្តល់សេវាសាធារណៈឌីជីថល | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៥.៤ | ផ្សព្វផ្សាយជាប្រចាំអំពីកាតព្វកិច្ច សិទ្ធិ ការទទួលខុសត្រូវ និងវិសាលភាព នៃការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍ ដែលមានកំណត់ក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៥.៥ | សហការនិងសម្របសម្រួលប្រតិបត្តិករនៅក្នុងប្រទេសឱ្យប្រើប្រាស់មជ្ឈមណ្ឌលផ្ទុកនិងចែកបញ្ញើប្រៃសណីយ៍ និងប្រព័ន្ធទិន្នន័យចែកបញ្ញើប្រៃសណីយ៍ | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៥.៦ | លើកទឹកចិត្តឱ្យប្រតិបត្តិករក្នុងវិស័យដឹកជញ្ជូនចុះកិច្ចសន្យាផ្តល់សេវាប្រៃសណីយ៍ ឬចុះកិច្ចសន្យាទទួលសិទ្ធិប្រកបអាជីវកម្ម (Franchise) ជាមួយសហគ្រាសប្រៃសណីយ៍កម្ពុជា | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |
| | | ៥.៧ | លើកទឹកចិត្តការចូលរួមវិនិយោគលើវិស័យប្រៃសណីយ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន ដើម្បីជំរុញការប្រកួតប្រជែង | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៥.៨ | - ជំរុញកិច្ចសហការ រវាងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងការកំណត់ក្របខណ្ឌវិធាន និងនីតិវិធីនៃការគ្រប់គ្រងលើការផ្តល់សេវាកម្មទទួល និងដឹកជញ្ជូនបញ្ញើរបស់ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងរថយន្តតាក់ស៊ីឯកជន ដោយក្នុងនោះអនុញ្ញាតឱ្យមានការផ្តល់សេវានេះក្នុងរយៈពេលខ្លី និងមធ្យមចំពោះមុខក្នុងលក្ខខណ្ឌដែលមានការ | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| | | | គ្រប់គ្រងល្អប្រសើរ និងច្បាស់លាស់<br>- ជាបណ្ដើរៗ សម្រាប់រយៈពេលវែងខាងមុខ រៀបចំអភិវឌ្ឍប្រព័ន្ធផ្ដល់សេវាបញ្ញើប្រៃសណីយ៍ស្របតាមស្តង់ដាឧត្តមានុវត្តន៍ជាអន្តរ-ជាតិ និងតម្រង់ទិសឱ្យអ្នកផ្ដល់សេវាកម្មបញ្ញើទាំងអស់ចូលរួមផ្ដល់សេវាផ្លូវការក្នុងប្រព័ន្ធមួយនេះ តាមរយៈការកែសម្រួលលិខិតបទ-ដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការគ្រប់គ្រង។ | | រយៈពេលវែង |
| ៦ | ជំរុញការបង្កើនសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជាក្នុងការធ្វើប្រតិបត្តិការអាជីវកម្ម | ៦.១ | កែទម្រង់ការងារនិងរៀបចំយុទ្ធសាស្ត្រធ្វើអាជីវកម្មផ្ដល់សេវា ដោយរួមបញ្ចូលទាំងការចាប់យកការដឹកជញ្ជូនសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក | ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី |
| | | ៦.២ | អភិវឌ្ឍបន្ថែមនូវបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងអាជីវកម្ម, អភិវឌ្ឍបច្ចេកវិទ្យាទទួលនិងចែកបញ្ញើប្រៃសណីយ៍, ធ្វើទំនើបកម្មមជ្ឈមណ្ឌលផ្លាស់ប្ដូរបញ្ញើប្រៃសណីយ៍, និងអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធគាំទ្រ ដល់ការដឹកជញ្ជូនសម្រាប់ពាណិជ្ជកម្មតាមប្រព័ន្ធ-អេឡិចត្រូនិក | ប្រៃសណីយ៍កម្ពុជា | រយៈពេលមធ្យម-វែង |
| | | ៦.៣ | គ្រប់គ្រងការដឹកបញ្ញើប្រៃសណីយ៍ ដោយអភិវឌ្ឍបន្ថែមនូវមធ្យោ-បាយ និងបច្ចេកទេសសម្រាប់គ្រប់គ្រងបញ្ញើប្រៃសណីយ៍ និងផ្លាស់ប្ដូរទិន្នន័យដឹកជញ្ជូនបញ្ញើប្រៃសណីយ៍ជាមួយដៃគូ | ប្រៃសណីយ៍កម្ពុជា | រយៈពេលមធ្យម |
| | | ៦.៤ | ធ្វើទំនើបកម្មសេវាប្រៃសណីយ៍រូបវន្តដែលមានស្រាប់ និងចូលរួមការផ្ដល់សេវាពហុមុខ | ប្រៃសណីយ៍កម្ពុជា | រយៈពេលមធ្យម |
| | | ៦.៥ | កសាងសមត្ថភាព បណ្ដុះបណ្ដាល និងតម្រង់ទិសដៅការងាររបស់និយោជិតគ្រប់ជាន់ថ្នាក់ និងបង្កើនសមត្ថភាពដល់និយោជិត | ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-មធ្យម |

| | | | | | |
|---|---|---|---|---|---|
| | | | ប្រើប្រាស់ ឧបករណ៍តាមបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន | | |
| | | ៦.៦ | ពង្រីកសាខាតំណាង ឬភ្នាក់ងាររហូតដល់ឃុំសង្កាត់ | ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |
| ៧ | បង្កើតកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល និងចូលរួមគាំទ្រផ្តល់សេវាសាធារណៈរបស់រាជរដ្ឋាភិបាល | ៧.១ | កំណត់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងការបំពេញកាតព្វកិច្ចសេវាប្រៃសណីយ៍សកល, កំណត់ប្រតិបត្តិករជាតិវិស័យប្រៃសណីយ៍ជាប្រតិបត្តិករសំខាន់ក្នុងការបំពេញកាតព្វកិច្ច, និងលើកទឹកចិត្តឱ្យប្រតិបត្តិករឯកជនចូលរួមអនុវត្តកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកលស្របតាមការកំណត់នៃបទប្បញ្ញត្តិ | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន | រយៈពេលខ្លី-វែង |
| | | ៧.២ | -កំណត់យន្តការគាំទ្រកាតព្វកិច្ចសេវាប្រៃសណីយ៍សកលចេញពីបណ្តាប្រភពគាំទ្រផ្សេងៗ ដែលរួមមានដៃគូអភិវឌ្ឍន៍ ការសហការជាមួយប្រតិបត្តិករឯកជននិងកិច្ចសហប្រតិបត្តិការផ្សេងៗទៀត<br>-ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចពិចារណាចាត់វិធានការជួយគាំទ្រដល់ការពង្រឹង និងការបង្កើនសមត្ថភាពរបស់ប្រតិបត្តិករជាតិក្នុងការអនុវត្តកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ក្រុមការងារនីតិកម្ម<br>- ប្រៃសណីយ៍កម្ពុជា<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍន៍ | រយៈពេលខ្លី-វែង |
| | | ៧.៣ | ជំរុញឱ្យប្រៃសណីយ៍កម្ពុជាចូលរួមក្នុងការផ្តល់សេវាសាធារណៈតាមរយៈការដឹកជញ្ជូននិងចែកបញ្ញើប្រៃសណីយ៍ ដើម្បីគាំទ្រសេវាច្រកចេញចូលតែមួយរបស់រាជរដ្ឋាភិបាល | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |
| | | ៧.៤ | ជំរុញប្រតិបត្តិករជាតិធ្វើការកែលម្អរបៀបរបបការងារ លើកកម្ពស់គុណភាពសេវាផ្នែកជួរមុខ បង្កើនសមត្ថភាពផ្នែកទ្រទ្រង់ កសាងសមត្ថភាពរបស់និយោជិត រៀបចំកិច្ចព្រមព្រៀងក្នុងការផ្តល់សេវាសាធារណៈ និងផ្តល់ព័ត៌មាននិងសេវាតាមប្រព័ន្ធអេឡិចត្រូនិក | ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |

| | | | | | |
|---|---|---|---|---|---|
| ៨ | ជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍ក្នុងវិស័យប្រៃសណីយ៍ | ៨.១ | រៀបចំនិងអនុវត្តកម្មវិធីសិក្សា និងទស្សនកិច្ចសិក្សាដល់អង្គភាពដែលពាក់ព័ន្ធនឹងអ្នកទទួលបន្ទុកការងារអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ | អគ្គនាយកដ្ឋានប្រៃសណីយ៍ | រយៈពេលខ្លី-វែង |
| | | ៨.២ | ជំរុញការបណ្តុះបណ្តាល និងការយល់ដឹងរបស់សាធារណជនលើចំណេះដឹងនិងជំនាញនៃវិស័យប្រៃសណីយ៍និងឌីជីថល | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |
| | | ៨.៣ | សម្របសម្រួលអភិវឌ្ឍសេវាប្រៃសណីយ៍ឌីជីថល សម្រាប់គាំទ្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ការដឹកជញ្ជូនគោលដៅចុង-ក្រោយ និងវឌ្ឍនភាពសង្គម | - អគ្គនាយកដ្ឋានប្រៃសណីយ៍<br>- ប្រៃសណីយ៍កម្ពុជា | រយៈពេលខ្លី-វែង |

## ឧបសម្ព័ន្ធ២ : គំនូសបំព្រួញស្តីពីគោលនយោបាយអភិវឌ្ឍន៍វិស័យប្រៃសណីយ៍ ២០២២-២០៣០

**ចក្ខុវិស័យ**

អភិវឌ្ឍវិស័យប្រៃសណីយ៍ និងទីផ្សារសេវាប្រៃសណីយ៍ ដើម្បីបម្រើធុរកិច្ចសហគ្រាស និងប្រជាជន ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងនវានុវត្តន៍ សំដៅចូលរួមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ

**គោលបំណង**

ពង្រឹង និងពង្រីកការផ្តល់សេវាប្រៃសណីយ៍ឱ្យបានទូលំទូលាយ ប្រកបដោយគុណភាព ប្រសិទ្ធភាព ប្រសិទ្ធផល សុវត្ថិភាព និងភាពជឿទុកចិត្ត ព្រមទាំងគាំទ្រការធ្វើពិពិធកម្មសេវាប្រៃសណីយ៍ និងការធ្វើអាជីវកម្មផ្តល់សេវាក្នុងវិស័យប្រៃសណីយ៍ ជាមួយនឹងការជំរុញការធ្វើទំនើបកម្ម និងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីរួមចំណែកទ្រទ្រង់ការអភិវឌ្ឍពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ចកម្ពុជា

**គោលដៅ**

- ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងវិស័យប្រៃសណីយ៍
- ធ្វើទំនើបកម្មសេវាប្រៃសណីយ៍
- បង្កលក្ខណៈងាយស្រួលដល់វិស័យឯកជន ក្នុងការធ្វើអាជីវកម្ម ក្នុងវិស័យប្រៃសណីយ៍
- លើកកម្ពស់តួនាទីរបស់ប្រៃសណីយ៍កម្ពុជាក្នុងការផ្តល់សេវាប្រៃសណីយ៍ រួមជាមួយនឹងការជំរុញនវានុវត្តន៍

**យុទ្ធសាស្ត្រ**

- ពង្រឹងក្របខណ្ឌគតិយុត្ត
- បង្កើតយន្តការលើកកម្ពស់គុណភាពសេវាប្រៃសណីយ៍
- លើកកម្ពស់សុវត្ថិភាពការងារ និងចីរភាពបរិស្ថាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញបរិវត្តកម្មឌីជីថល
- គ្រប់គ្រងឱ្យបានល្អប្រសើរនូវការធ្វើអាជីវកម្មរបស់វិស័យឯកជន
- ជំរុញការបង្កើនសមត្ថភាពរបស់ប្រៃសណីយ៍កម្ពុជា
- បង្កើតកម្មវិធីកាតព្វកិច្ចសេវាប្រៃសណីយ៍សកល
- ជំរុញការកសាងសមត្ថភាព ការស្រាវជ្រាវ និងនវានុវត្តន៍

**ផែនការសកម្មភាព**

- ការបង្កើតយន្តការសហការ សម្របសម្រួល និងអនុវត្ត
- កិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិ
- ការពង្រឹងក្របខណ្ឌគតិយុត្ត
- ការគាំទ្រហិរញ្ញវត្ថុ
- ការបណ្តុះបណ្តាលធនធានមនុស្ស
- ដំណើរការអនុវត្តគម្រោង

**ឧបសម្ព័ន្ធ៣ : លំដាប់លេខរៀងនៃសន្ទស្សន៍សម្រាប់ការអភិវឌ្ឍប្រៃសណីយ៍២០២១ នៅតាមបណ្ដាប្រទេសអាស៊ាន**

| លំដាប់លេខរៀងក្នុងចំណោម១៦៨ប្រទេស | ឈ្មោះប្រទេស | ពិន្ទុ |
|---|---|---|
| ១០ | សឹង្ហបុរី | ៧៧,១ |
| ២៣ | ម៉ាឡេស៊ី | ៦២,១ |
| ៣០ | ថៃ | ៥៩ |
| ៤៧ | វៀតណាម | ៤៨ |
| ៦៦ | ឡាវ | ៣៦,២៣ |
| ៦៧ | ឥណ្ឌូនេស៊ី | ៣៥,៩២ |
| ៨៤ | កម្ពុជា | ២៨,៦៨ |
| ៨៦ | ហ្វីលីពីន | ២៨,២៤ |
| ១២២ | មីយ៉ាន់ម៉ា | ១៣,៩៤ |
| ១៦៤ | ប្រ៊ុយណេ | ៤ |

*ប្រភព : របាយការណ៍អភិវឌ្ឍន៍ប្រៃសណីយ៍២០២១ របស់សហភាពប្រៃសណីយ៍សកល*

## ឧបសម្ព័ន្ធ៤ : សទ្ទានុក្រម

| បច្ចេកសព្ទ | ភាសាអង់គ្លេស | សេចក្តីពន្យល់ |
| --- | --- | --- |
| កាតព្វកិច្ចសេវាប្រៃសណីយ៍សកល | Universal Postal Service Obligation | កាតព្វកិច្ចដែលត្រូវផ្តល់ជូនប្រជាជនទូទាំងប្រទេសនូវសេវាប្រៃសណីយ៍សកល។ |
| ការដឹកជញ្ជូនគោលដៅចុងក្រោយ | Last-Mile Delivery | ការចែកបញ្ញើដល់អ្នកប្រើប្រាស់ចុងក្រោយ តាមរយៈមធ្យោបាយផ្សេងៗ ដោយកំណត់ពេលវេលាជាក់លាក់ ឆាប់រហ័ស និងមានប្រព័ន្ធតាមដានដោយស្វ័យប្រវត្តិ។ |
| នវានុវត្តន៍សេវាប្រៃសណីយ៍ | Postal Service Innovation | ការបង្កើតសេវាឬផលិតផលប្រៃសណីយ៍ថ្មីៗ ឬការបង្កើនគុណភាពសេវា ឬ ផលិតផលប្រៃសណីយ៍ដែលមានស្រាប់តាមរយៈការផ្តល់ជូននូវលក្ខណៈពិសេសថ្មីៗ។ |
| បញ្ញើប្រៃសណីយ៍ | Postal Mail | ជាកម្មវត្ថុ នៃការធ្វើអាជីវកម្មរបស់ប្រតិបត្តិករជាតិ និងប្រតិបត្តិករឯកជន ដោយមានវិសាលភាពគ្របដណ្តប់លើបណ្តាបញ្ញើមានលក្ខណៈជាលិខិត ឯកសារ ឬ សម្ភារៈដាក់ក្នុងសំបុត្រ កញ្ចប់តូច កញ្ចប់ធំ និងប្រភេទបញ្ញើផ្សេងៗទៀតដែលមានអាសយដ្ឋាន លេខទូរស័ព្ទ លេខកូដ សញ្ញាសម្គាល់តាមបែបព័ត៌មានវិទ្យា ឬ សញ្ញាសម្គាល់ផ្សេងៗទៀតរបស់អ្នកផ្ញើនិងអ្នកទទួល ដែលមិនមានម្ចាស់ទៅជាមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងនិងការកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន ដោយមានការសម្របសម្រួលជាមួយក្រសួងសាធារណការ និងដឹកជញ្ជូន។ |
| បណ្តាញប្រៃសណីយ៍ | Postal Network | ទីតាំង សម្ភារៈ ធនធាន និងប្រព័ន្ធគ្រប់គ្រង ទទួល ប្រមូលតម្រៀបបែងចែក ដឹកជញ្ជូន និងចែកចាយ ដែលត្រូវបានផ្សារភ្ជាប់គ្នាដើម្បីបម្រើឱ្យការធ្វើអាជីវកម្មសេវាប្រៃណីយ៍។ |
| ប្រព័ន្ធអេកូឡូហ្ស៊ីប្រៃសណីយ៍ឌីជីថល | Digital Postal Ecology | ប្រព័ន្ធឌីជីថលដែលត្រូវបានរៀបចំឱ្យមានលក្ខណៈសុខដុមនីយកម្ម តាមរយៈបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានជាមួយភាគីដែលពាក់ព័ន្ធ ដើម្បីសម្រួលនិងគាំទ្រដល់ប្រតិបត្តិការសេវាប្រៃសណីយ៍តាមប្រព័ន្ធអេឡិចត្រូនិក។ |
| ភស្តុភារកម្មប្រៃសណីយ៍ | Postal Logistics | បណ្តាញប្រៃសណីយ៍ សម្រាប់ទ្រទ្រង់ការទទួលបញ្ញើពី |

| | | |
|---|---|---|
| | | ចំណុចចាប់ផ្ដើម និងដឹកជញ្ជូន រហូតដល់ការចែកដល់គោលដៅចុងក្រោយ ដោយមានប្រព័ន្ធតាមដានដោយស្វ័យប្រវត្តិ និងកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ |
| សហភាពប្រៃសណីយ៍សកល | Universal Postal Union | ភ្នាក់ងារឯកទេសរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៧៤ ជាមួយឈ្មោះដំបូងគឺ សហភាពប្រៃសណីយ៍ទូទៅ (General Postal Union) និងបានប្ដូរឈ្មោះទៅជាសហភាពប្រៃសណីយ៍សកលនៅឆ្នាំ១៨៧៨។ សហភាពប្រៃសណីយ៍សកលដែលមានសមាជិក ១៩២ ប្រទេស ក្នុងនោះព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិក នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៥១ ជាវេទិកាអន្តរជាតិចម្បងសម្រាប់កិច្ចសហប្រតិបត្តិការរវាងតួអង្គសំខាន់ៗក្នុងវិស័យប្រៃសណីយ៍លើពិភពលោក សំដៅធានានិរន្តរភាពនៃបណ្ដាញផ្ដល់សេវាប្រៃសណីយ៍អន្តរជាតិ។ |
| សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក | Asian-Pacific Postal Union | សហភាពប្រៃសណីយ៍ប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៦១ស្របតាមមាត្រា៨នៃធម្មនុញ្ញរបស់សហភាពប្រៃសណីយ៍សកល។ សហភាពប្រៃសណីយ៍អាស៊ីប៉ាស៊ីហ្វិក ដែលមានសមាជិក ៣២ ប្រទេស ក្នុងនោះព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិក នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩៧ មានបេសកកម្មពង្រឹងការអភិវឌ្ឍវិស័យប្រៃសណីយ៍ និងទំនាក់ទំនង រវាងបណ្ដាប្រទេសជាសមាជិក ដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការក្នុងវិស័យប្រៃសណីយ៍។ |
| សេវាបញ្ញើឆាប់រហ័ស | Courier Service | សេវាប្រៃសណីយ៍ដែលផ្ដល់ដោយប្រតិបត្តិករឯកជន ដោយភ្ជាប់ជាមួយលក្ខខណ្ឌអាទិភាព សុវត្ថិភាព ឆាប់រហ័ស អាចតាមដានបានដោយប្រព័ន្ធព័ត៌មានវិទ្យា និងកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ |
| សេវាបញ្ញើប្រៃសណីយ៍ឆាប់រហ័ស | Express Mail Service (EMS) | សេវាប្រៃសណីយ៍ដែលផ្ដល់ដោយប្រតិបត្តិករជាតិ ដោយភ្ជាប់ជាមួយលក្ខខណ្ឌអាទិភាព សុវត្ថិភាព ឆាប់រហ័ស អាចតាមដានបានដោយប្រព័ន្ធព័ត៌មានវិទ្យា និងកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ |

| | | |
|---|---|---|
| សេវាប្រៃសណីយ៍សកល | Universal Postal Service | សេវាប្រៃសណីយ៍មូលដ្ឋានប្រកបដោយគុណភាព តម្លៃសមរម្យ និងនិរន្តរភាព ដែលប្រជាជនទូទាំងប្រទេសមានសិទ្ធិទទួលបានជាចាំបាច់ ដើម្បីបម្រើឱ្យការងារទំនាក់ទំនងនិងជីវភាពរស់នៅប្រចាំថ្ងៃ។ |
| សេវាប្រៃសណីយ៍ឌីជីថល | Digital Postal Service | សេវាប្រៃសណីយ៍បម្រើជូនអ្នកប្រើប្រាស់តាមរយៈប្រព័ន្ធបច្ចេកវិទ្យាឌីជីថល និងអាចគាំទ្រដល់រដ្ឋាភិបាលឌីជីថល (Digital Government), ពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce) និងសេវាផ្សេងទៀតតាមប្រព័ន្ធអ៊ីនធឺណិត។ |

# គោលនយោបាយ
# អភិវឌ្ឍន៍វិស័យប្រៃសណីយ៍
# ២០២២-២០៣០